ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# ច្បាប់

# ស្ដីពី

# ជលផល

# ព្រះរាជក្រម

នស/រកម/០៥០៦/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះស្របតាមមាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះមានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផល ជំរុញកិច្ចអភិវឌ្ឍន៍វារីវប្បកម្ម ផលិតកម្ម និងការកែច្នៃ លើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ដើម្បីផលប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន រួមទាំងការអភិរក្សជីវចម្រុះផង ទាំងមរតកវប្បធម៌ធម្មជាតិផង ប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.–**

ច្បាប់នេះមានវិសាលភាពអនុវត្តលើជលផលទាំងអស់ ទាំងប្រភេទជលផលដែលកើតឡើងដោយធម្មជាតិ ទាំងជលផលកែច្នៃ និងទាំងវារីវប្បកម្ម ។

រដ្ឋធានាសិទ្ធិប្រើប្រាស់ធនធានជលផលជាប្រពៃណីរបស់សហគមន៍មូលដ្ឋានក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ច្បាប់ពាក់ព័ន្ធផ្សេងទៀត ។

**មាត្រា ៣.–**

ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាងដែលពាក់ព័ន្ធនឹងវដ្តជីវិតនៃធនធានជលផល ត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ ។

រដ្ឋផ្តល់សិទ្ធិគ្រប់គ្រងតំបន់ការពារធម្មជាតិដល់ក្រសួងបរិស្ថាន ក្រោមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ និងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀត ។

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តច្បាប់ចំពោះរាល់បទល្មើសជលផលដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិ

ក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ ។ សកម្មភាពនេះនឹងមិនធ្វើឱ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថានដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ ។

**មាត្រា ៤.–**

ធនធានជលផលមានសរីរាង្គទឹកសាប និងសមុទ្រ ជាសត្វ និងរុក្ខជាតិមានជីវិត ឬគ្មានជីវិត ជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតដែលបង្កកំណើតនៅក្នុងទឹក ប្លង់តុង សារាយ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃលិចទឹក ព្រមទាំងព្រៃកោងកាងជាដើម ។

**មាត្រា ៥.–**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## រដ្ឋបាលជលផល

**មាត្រា ៦.–**

រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផលស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ ។ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផលត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា ៧.–**

អនុលោមតាមគោលការណ៍តម្លាភាពដោយធានានូវសិទ្ធិសាធារណៈ ដើម្បីចូលរួមក្នុងការធ្វើសេចក្ដីសម្រេចលើការគ្រប់គ្រង ការប្រើប្រាស់ ការអភិរក្ស និងអភិវឌ្ឍន៍ជលផលប្រកបដោយនិរន្តរភាព រដ្ឋបាលជលផលមានមុខងារសំខាន់ៗដូចតទៅ :

-ការងាររដ្ឋបាលរួមមាន ការគ្រប់គ្រងរដ្ឋបាល ការចាត់ចែងរាល់សកម្មភាពជលផល និងអភិវឌ្ឍន៍សហគមន៍នេសាទ

-ការងារបច្ចេកទេសរួមមាន ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ អភិរក្សអភិវឌ្ឍន៍សេដ្ឋកិច្ច បច្ចេកវិទ្យាជលផល និងបច្ចេកវិទ្យាដែលពាក់ព័ន្ធនឹងជលផល ព្រមទាំងការបង្កើនវារីវប្បកម្ម

-ការងារអនុវត្តច្បាប់រួមមាន ការងារអធិការកិច្ច ការអង្កេត ការតាមដាន និងការត្រួតពិនិត្យរាល់សកម្មភាពជលផលក្នុងតួនាទីជានគរបាលយុត្តិធម៌ ។

## ជំពូកទី ៣
## ដែននេសាទ

**មាត្រា ៨.–**

ដែននេសាទរួមមាន ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទ និងការការពារប្រព័ន្ធអេកូឡូស៊ីជលផល ។

ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ ។

ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្ដៅ វាលភក់ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវជំនោរឡើង និងនាទីព្រៃលិចទឹក ។

ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង ។

**មាត្រា ៩.-**

ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ព្រំប្រទល់នៃដែននេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

រាល់ការប្រើប្រាស់ដែននេសាទដើម្បីគោលបំណងក្រៅវិស័យជលផល ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ដែននេសាទអាចគ្របដណ្តប់លើដីសាធារណៈ ឬ ដីកម្មសិទ្ធិឯកជននារដូវដំឡើង ប៉ុន្តែការគ្រប់គ្រងជលផលមិនប៉ះពាល់ដល់ដីកម្មសិទ្ធិទាំងនោះឡើយ ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ដែននេសាទទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដើម្បីធ្វើអាជីវកម្មនេសាទ ប្រមូលធនធានជលផល ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ឬ តម្រូវការចាំបាច់ផ្សេងៗទៀត ។

**មាត្រា ១០.-**

ដែននេសាទទឹកសាប គឺជាផ្ទៃទឹកដែលលាតសន្ធឹងចាប់ពីដែននេសាទសមុទ្ររហូតដល់ព្រំប្រទល់ដីគោកនៃព្រះរាជាណាចក្រកម្ពុជា ។

ដែននេសាទទឹកសាបចែកជា :

-ឡូត៍នេសាទដែលទុកសម្រាប់សម្បទានដល់ការវិនិយោគ ឬ ជួលឱ្យធ្វើអាជីវកម្មនេសាទ

-កន្លែងអភិរក្សជលផលដែលជាជម្រករក្សាពូជវារីសត្វ និងវារីរុក្ខជាតិ

-នាទីព្រៃលិចទឹករួមមាន តំបន់ព្រៃលិចទឹកដែលជាជម្រកចាំបាច់របស់វារីសត្វក្នុងការស្វែងរកចំណី ឬ កន្លែងពងកូន និងតំបន់លិចទឹកដែលត្រូវការពារ

-កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ

-កន្លែងនេសាទបម្រុង ជាកន្លែងនេសាទទាំងឡាយដែលពុំបានធ្វើការចាត់ថ្នាក់

-កន្លែងនេសាទសម្រាប់អភិវឌ្ឍវារីវប្បកម្ម

-ទំនាបលិចទឹកក្នុងរដូវដំឡើង ។

**មាត្រា ១១.-**

ដែននេសាទសមុទ្រ គឺជាផ្ទៃទឹកសមុទ្រ ឬ ទឹកភ្លាវដែលលាតសន្ធឹងពីខ្សែបន្ទាត់ដែលទឹកជោរខ្ពស់បំផុតនៃតំបន់ឆ្នេរ រហូតដល់ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា ។

ដែននេសាទសមុទ្រចែកជា:

-កន្លែងនេសាទតាមឆ្នេរ ដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតរហូតដល់ខ្សែបន្ទាត់ដែលមានជម្រៅទឹកម្ភៃ(២០)ម៉ែត្រ

-កន្លែងនេសាទសមុទ្រខាងក្រៅ ដែលលាតសន្ធឹងពីខ្សែបន្ទាត់ដែលមានជម្រៅទឹកម្ភៃ (២០)ម៉ែត្រ រហូតដល់ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា

-កន្លែងអភិរក្សជលផល តំបន់ស្មៅសមុទ្រ និងតំបន់ផ្កាថ្ម ជាជម្រករក្សាពូជវារីសត្វ និងវារីរុក្ខជាតិ

-នាទីព្រៃកោងកាងរួមមានតំបន់ព្រៃកោងកាង និងព្រៃទាំងអស់ដែលជាជម្រកចាំបាច់របស់វារីសត្វក្នុងការស្វែងរកចំណី ឬ កន្លែងពងកូន និងតំបន់លិចទឹកដែលត្រូវការពារ ។

**មាត្រា ១២.-**

កន្លែងនេសាទគ្រប់ប្រភេទ កន្លែងអភិរក្សជលផល តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម ទំនាបលិចទឹកក្នុងរដូវជំនោរឡើង នាទីព្រៃលិចទឹក និងនាទីព្រៃកោងកាងដូចមានចែងក្នុងមាត្រា១០ និងមាត្រា១១ នៃច្បាប់នេះ គឺជាតំបន់គ្រប់គ្រងជលផល ។

ការបង្កើត ការរំសាយតំបន់គ្រប់គ្រងជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

នីតិវិធីនៃការបង្កើត ឬ រំសាយតំបន់គ្រប់គ្រងជលផលត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៣.-**

ការផ្តល់កម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់គ្រប់គ្រងជលផលអាចប្រព្រឹត្តទៅបានលុះត្រាតែមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

# ជំពូកទី ៤
# និរន្តរភាពនៃការគ្រប់គ្រងជលផល

**មាត្រា ១៤.-**

ការគ្រប់គ្រងជលផលប្រកបដោយនិរន្តរភាព ត្រូវអនុវត្តស្របតាមគោលនយោបាយវិស័យជលផលជាតិ និងខ្លឹមសារនៃច្បាប់នេះ ។

ដើម្បីជំនួយឱ្យការសិក្សាស្រាវជ្រាវ និងការកំណត់គោលនយោបាយវិស័យជលផលជាតិឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាលត្រូវបង្កើតគណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យជលផលជាតិដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានសមាជិកពីក្រសួងពាក់ព័ន្ធ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យជលផលជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

រដ្ឋបាលជលផល ត្រូវបានទទួលថវិកាចំណូលពីវិស័យជលផលជាអាទិភាព តាមនីតិវិធីហិរញ្ញវត្ថុ សម្រាប់បំរើការងារកែទម្រង់វិស័យជលផល ស្រាវជ្រាវ អភិរក្ស និងថែរក្សាធនធានជលផលប្រកបដោយនិរន្តរភាព ។

**មាត្រា ១៥.-**

រដ្ឋបាលជលផល ត្រូវរៀបចំផែនការគ្រប់គ្រងវិស័យជលផលជាតិស្របតាមគោលនយោបាយវិស័យជលផលជាតិ ដោយមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន ។

ផែនការគ្រប់គ្រងវិស័យជលផលជាតិ ត្រូវសម្រេចដោយរាជរដ្ឋាភិបាលសម្រាប់រយៈពេលវែងដើម្បីកំណត់អាទិភាព និងសកម្មភាពគ្រប់គ្រងជលផល ។ ផែនការគ្រប់គ្រងវិស័យជលផលជាតិត្រូវធ្វើការពិនិត្យ និងសើរើរៀងរាល់ប្រាំ(៥)ឆ្នាំម្តង ដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌ និងកាលៈទេសៈផ្លាស់ប្តូរ ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យជលផលជាតិ ត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការគ្រប់គ្រងវិស័យជលផលជាតិដែលបានសើរើ ។

ផែនការគ្រប់គ្រងវិស័យជលផលជាតិ ត្រូវលើកឡើងនូវគោលការណ៍សំខាន់ៗដូចតទៅ:

-អភិរក្សធនធានជលផល

-ជំរុញឱ្យប្រជាពលរដ្ឋចូលរួមគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព

-លុបបំបាត់ការធ្វើនេសាទហួសកម្រិត

-បន្ថយជាអតិបរមានូវកម្រិតសារធាតុពុលក្នុងដែននេសាទ

-ការពារជីវចម្រុះ និងបរិស្ថានទឹកសាប និងសមុទ្រ

-ថែរក្សា ការពារព្រៃលិចទឹក និងព្រៃកោងកាង និងកែលំអដែននេសាទ

-ទប់ស្កាត់ការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋនៅក្នុងដែននេសាទ

-លើកកម្ពស់ផលប្រយោជន៍អ្នកនេសាទ

-ដោះស្រាយទំនាស់នៃការប្រើប្រាស់ដែននេសាទ

-គ្រប់គ្រងដោយផ្អែកលើវិទ្យាសាស្ត្រក្នុងការធានារក្សាផលស្តុកដើម្បីទទួលទិន្ន-ផលនិរន្តរភាពអតិបរមា

-ពង្រឹងអង្គភាពគ្រប់គ្រងវិស័យជលផលនៅគ្រប់ថ្នាក់ កែលំអ និងពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល

-អភិវឌ្ឍទីផ្សារ ឧស្សាហកម្មកែច្នៃ និងកំពង់ផែនេសាទ

-អភិវឌ្ឍការធ្វើវារីវប្បកម្មតាមគ្រប់រូបភាព

-ស្រាវជ្រាវ ពិនិត្យ តាមដានកត្តារូបសាស្ត្រ បរិស្ថាន និងសង្គម ទាក់ទងនឹងធនធានជលផលនៅគ្រប់ថ្នាក់នៃរដ្ឋបាលជលផល

-អភិវឌ្ឍកម្មវិធីស្រាវជ្រាវស្តីពីការអភិវឌ្ឍបច្ចេកវិជ្ជា និងវិទ្យាសាស្ត្រជលផល

-បង្កើន និងពង្រីកចំណេះដឹងពីជលផលដោយមានការចូលរួមពីសហគមន៍មូលដ្ឋានក្នុងការគ្រប់គ្រងប្រើប្រាស់ និងការពារជលផល

-អភិវឌ្ឍធនធានមនុស្ស និងមធ្យោបាយសម្ភារៈចាំបាច់ដើម្បីសម្រេចលើសកម្មភាពដែលបានគ្រោងនៅក្នុងកម្មវិធី

-ពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ជំនួយបច្ចេកទេសក្នុងតំបន់ និងក្រៅតំបន់ក្នុងកិច្ចការពារ និងអភិវឌ្ឍន៍ធនធានជលផលជាតិ

-ឧបត្ថម្ភគាំទ្រ រាល់កម្មវិធីទាំងឡាយណា ដែលជំរុញឱ្យមានការអនុវត្តគោលនយោបាយវិស័យជលផលជាតិ ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តនូវគោលបំណងនៃផែនការគ្រប់គ្រងវិស័យជលផលជាតិជូនរាជរដ្ឋាភិបាល ។

របាយការណ៍នេះ ត្រូវផ្តល់ជូនជាសាធារណៈតាមការស្នើសុំ ។

## មាត្រា ១៦.–

រដូវបិទនេសាទសម្រាប់ការនេសាទសិប្បកម្មត្រូវកំណត់ដូចខាងក្រោម ៖

១-ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ដល់ថ្ងៃទី ៣០ ខែ កញ្ញា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ (រយៈទទឹង ៖ ១១° ៣៣,២៥៩ ' ជើង) ។

២-ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ដល់ថ្ងៃទី ៣១ ខែ តុលា ចំពោះដែននេសាទទឹកសាបដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ (រយៈទទឹង ៖ ១១° ៣៣,២៥៩ ' ជើង) ។

រដ្ឋបាលជលផល ត្រូវទទួលបន្ទុកស្រាវជ្រាវ និងតាមដានរដូវត្រីពងកូន រដូវនេសាទសម្រាប់តំបន់ ឬ ប្រភេទធនធានជលផលដទៃទៀត ។

រដូវត្រីពងកូន រដូវនេសាទសម្រាប់តំបន់ ឬ ប្រភេទធនធានជលផលដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ១៧.–

ដើម្បីជំរុញការអប់រំប្រជាពលរដ្ឋឱ្យយល់ពីសារៈសំខាន់ និងផលប្រយោជន៍នៃជលផលទិវាលែងត្រី ឬ វារីសត្វជាប្រពៃណីជាតិហៅថា **ទិវាមច្ឆជាតិ** ត្រូវប្រារព្ធធ្វើឡើងនៅថ្ងៃទី ០១ ខែកក្កដាជារៀងរាល់ឆ្នាំ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬ ព្រះរាជតំណាង ។

## ជំពូកទី ៥
## ការការពារ និងអភិរក្សជលផល

**មាត្រា ១៨.–**

តំបន់គ្រប់គ្រងជលផលជាអាទិ៍ តំបន់ទឹកជ្រៅ អន្លង់ជ្រៅៗនៅតាមដងទន្លេ បឹងទន្លេសាប បឹង ព្រៃលិចទឹក តំបន់កោះ តំបន់ស្មៅសមុទ្រ តំបន់ផ្កាថ្ម និងព្រៃកោងកាង ដែលជាកន្លែងមានសារៈសំខាន់ដល់និរន្តរភាពនៃធនធានជលផល ត្រូវរៀបចំចាត់ថ្នាក់ជាកន្លែងការពារ និងអភិរក្សធនធានជលផល ។

**មាត្រា ១៩.–**

ហាមឃាត់ :

១-ការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងកន្លែងអភិរក្សជលផល លើកលែងតែមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់រដ្ឋបាលជលផលធ្វើការពិសោធន៍ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ។

២-ការធ្វើនាវាចរណ៍ឆ្លងកាត់ ឬ ធ្វើសកម្មភាពផ្សេងទៀតក្នុងកន្លែងអភិរក្សជលផល លើកលែងតែមន្ត្រីមានសមត្ថកិច្ចនៅពេលដែលចាំបាច់ក្នុងការអនុវត្តច្បាប់ ។

៣-ការតាំងទីលំនៅថ្មីដែលស្ថិតនៅតិចជាងពីរ (២) គីឡូម៉ែត្រពីព្រំប្រទល់កន្លែងអភិរក្សជលផល លើកលែងតែទីលំនៅរបស់រដ្ឋបាលជលផលដែលប្រើសម្រាប់គោលបំណងអនុវត្តច្បាប់ ។

**មាត្រា ២០.–**

ហាមឃាត់ដាច់ខាត ចំពោះការធ្វើនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទ ដោយប្រើឧបករណ៍ដូចខាងក្រោម :

១-ឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទ ។

២-ឧបករណ៍បូម បាច ពង្រីងផ្នែកណាមួយនៃដែននេសាទដែលបង្កមហន្តរាយដល់ធនធានជលផល ។

៣-សម្រាស់ ឬ មធ្យោបាយផ្សេងទៀតដែលធ្វើឱ្យត្រី ឬ វារីសត្វកុំ ។

៤-ចំប្រូក សាង ស្ន ឬ ឧបករណ៍បាញ់ព្រួញដែលរួមផ្សំគ្រឿងផ្ទុះ ។

៥-មងបោះ មងកាំង ឬ មងពស់ថ្នាន់គ្រប់ប្រភេទ ។

៦-មង ឬ អួនគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១,៥ ស.ម) ក្នុងដែននេសាទទឹកសាប ។

៧-មងគ្រប់ប្រភេទដែលមានក្រឡាធំជាងដប់ប្រាំ (១៥) សង្ទីម៉ែត្រក្នុងដែននេ-សាទទឹកសាប ។

៨-អួនអួសត្វ ឬ អួនហ៊ុមរួមផ្សំភ្លើងដែលធ្វើឱ្យត្រី ឬ វារីសត្វកុំ ។

៩-ឧបករណ៍នេសាទស្នែមុងគ្រប់ប្រភេទនៅទឹកសាប ។

១០-អួនអួសគ្រប់ប្រភេទនៅទឹកសាប និងឈិបយន្ត ។

១១-ព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀមមួយតូចជាងមួយសង្ទីម៉ែត្រកន្លះ(១,៥ស.ម) ។

១២-ខ្សែចងគ្រប់ប្រភេទ និងមធ្យោបាយផ្សេងៗទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល ។

១៣-ទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទ ។

១៤-ឧបករណ៍នេសាទទំនើប ឬ ឧបករណ៍នេសាទដែលបង្កើតថ្មី ឬ របៀបនេសាទបែបថ្មីដែលនាំមកនូវការបំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ឬ ដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២១.–**

ហាមឃាត់ ការផលិត ការទិញ ការលក់ ការដឹកជញ្ជូន ការរក្សាទុកឧបករណ៍ឆក់ ឧបករណ៍នេសាទស្នែមុងគ្រប់ប្រភេទ អួនអួសត្វ ឈិបយន្ត និងអួនអួសទឹកសាប ក្នុងបំណងធ្វើនេសាទ ។

**មាត្រា ២២.–**

ហាមឃាត់ ការចាក់ចោល ការបោះចោល ការបង្ហូរ ឬ ការបាចពង្រាយទៅក្នុងដែននេសាទនូវកាកសំណល់រឹង ឬ រាវ ឬ សារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិត

បទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញា ឬ សន្ធិសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬ ការប្រព្រឹត្តសកម្មភាពដែលធ្វើឱ្យពុល ឬ ការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ ។

## មាត្រា ២៣.–

សកម្មភាពដូចខាងក្រោមអាចប្រព្រឹត្តទៅបានលុះត្រាតែមានការអនុញ្ញាត :

១-ការចាប់ ការលក់ ការទិញ ការធ្វើសន្និធិ និងការដឹកជញ្ជូនកូន ឬ ពងត្រី និងកូន ឬ ពងវារីសត្វផ្សេងៗទៀត ។

២-ការចាប់ ការលក់ ការទិញ ការដឹកជញ្ជូន ការប្រមូលផល ការកែច្នៃ និងការធ្វើសន្និធិនូវប្រភេទធនធានជលផលកំពុងរងគ្រោះថ្នាក់ ។

៣-ការដាំ ឬ ការថែរក្សាដំណាំឈូកក្នុងដែននេសាទ ។

៤-ការពង្រីកផ្ទៃដីស្រែចម្ការ ឬ ស្រែអំបិលក្នុងដែននេសាទ ។

៥-ការគាស់ ការកកាយយកថ្ម ដីខ្សាច់ និងរ៉ែ ដែលមាននៅក្នុងដែននេសាទ ។

៦-ការទិញ ឬ ការលក់សំបកពពួកខ្យងខ្មៅតាំងលំអដែលជាប្រភេទកម្រ ។

៧-ការនេសាទដោយឧបករណ៍ម៉ាញ់ នាម ជន មងក្រឡុក មងអួស ឈ្នាងអួសលៀស ឬ ខ្មៅនៅទឹកសាប និងឈ្នាងអួសគ្រែងឈាមនៅតំបន់ឆ្នេរសមុទ្រ ដែលអួស ឬ រុញដោយកម្លាំងម៉ាស៊ីន ។

ទំហំកូនត្រី វារីសត្វផ្សេងៗទៀត និងប្រភេទសំបកខ្យងខ្មៅតាំងលំអដែលជាប្រភេទកម្រ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ២៤.–

ហាមឃាត់:

១-ការបោះបង្គោលបង្កើតឡូត៍នេសាទថ្មីដោយគ្មានការអនុញ្ញាត ។

២-ការផ្លាស់ប្តូរ ការរំកិល ការជីកកប់ ឬ ការបំផ្លាញបង្គោលព្រំប្រទល់នៃតំបន់គ្រប់គ្រងជលផល ។

៣-ការនេសាទគ្រប់ប្រភេទធ្វើឱ្យរាំងស្ទះចរាចរណ៍ត្រីចុះនៅតំបន់កបឹងទន្លេសាប ។

៤-ការនេសាទដោយលបបណ ឬ វ៉ាវក្រៅតំបន់កំណត់ ។

៥-ការធ្វើអាជីវកម្មនេសាទ ការធ្វើវារីវប្បកម្ម ការដឹកជញ្ជូន ការកែច្នៃ និងសន្និធិផល ផលិតផលជលផល ខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ។

៦-ការបង្កើតទីតាំងទិញ លក់ សន្និធិ ផែត្រី កន្លែងកែច្នៃផល ផលិតផលជលផលជាលក្ខណៈសិប្បកម្ម ឬ ឧស្សាហកម្មខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ។

៧-ការប្រើប្រាស់ឧបករណ៍នេសាទ និងមធ្យោបាយគ្រប់ប្រភេទខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ។

៨-ការផ្ទេរលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាតពីរដ្ឋបាលជលផល ។

៩-ការធ្វើសកម្មភាពដទៃទៀតនៅក្នុងដែននេសាទដែលបង្កអន្តរាយដល់ប្រភពធនធានជលផល ។

**មាត្រា ២៥.–**

ការធ្វើទំនប់កាត់ ឬ ការលុបទន្លេ ស្ទឹង ព្រែក អូរ បឹង ប្រឡាយ អាងទឹក និង អាងធម្មជាតិ ឬ ការជីកប្រឡាយ រណ្ដៅ និងស្រះទ្រង់ទ្រាយធំ ឬ ការសាងសង់សំណង់ថ្មីនានា ឬ ការបូមទឹកដែលអាចបង្កមហន្តរាយដល់ធនធានជលផលនៅក្នុងដែននេសាទ ត្រូវមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី ៦
## ការគ្រប់គ្រងនាទីព្រៃលិចទឹក និងព្រៃកោងកាង

**មាត្រា ២៦.–**

ហាមបង្កភ្លើងឆេះព្រៃក្នុងនាទីព្រៃលិចទឹក និងព្រៃកោងកាង ។ រដ្ឋបាលជលផលអាចប្រើប្រាស់ភ្លើងសម្រាប់ផលប្រយោជន៍រុក្ខវប្បកម្ម ឬ អនាម័យព្រៃលិចទឹក និងព្រៃកោងកាង ។

គោលការណ៍ណែនាំក្នុងការកំណត់តំបន់ត្រួតពិនិត្យភ្លើងឆេះព្រៃលិចទឹក និងព្រៃកោងកាង ការការពារភ្លើងឆេះ និងការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងភ្លើងឆេះព្រៃលិចទឹក និងព្រៃកោងកាងសម្រាប់ជាវិធានការអនុវត្តនៅគ្រប់នាទីព្រៃលិចទឹក និងព្រៃកោងកាង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រជាពលរដ្ឋ សហគមន៍នេសាទ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់ថ្នាក់ ត្រូវមានករណីយកិច្ចចូលរួមថែរក្សាជម្រកមច្ឆជាតិ ការពារ បង្ការ និងប្រយុទ្ធនឹងភ្លើងឆេះព្រៃលិចទឹក និងព្រៃកោងកាង ។

**មាត្រា ២៧._**

តំបន់លិចទឹកដែលត្រូវការពារមានជាអាទិ៍ ដីលិចទឹកដែលស្ថិតនៅក្នុងនាទីឡូត៍នេសាទ និងស្ថិតនៅក្នុងនាទីព្រៃលិចទឹក និងព្រៃកោងកាងដែលត្រូវការពារសម្រាប់ដាំ ឬ រក្សាទុកឱ្យដុះព្រៃឡើងវិញ ដើម្បីរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីជលផល ។

**មាត្រា ២៨._**

ហាមឃាត់ :

១-ការពង្រីកផ្ទៃដីកសិកម្ម ឬ ការប្រើប្រាស់ដីក្នុងបំណងផ្សេងៗ ក្រៅពីកិច្ចអភិវឌ្ឍន៍វិស័យជលផលនៅក្នុងតំបន់លិចទឹកដែលត្រូវការពារស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-ការផ្តល់កម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ដីធ្លីនៅក្នុងតំបន់លិចទឹកដែលត្រូវការពារ ។

៣-ការកាប់ ការឆ្ការ ការគាស់ ការរាន ការឈូសឆាយ ការដុត ឬ ការហ៊ុមព័ទ្ធកាន់កាប់ព្រៃលិចទឹក និងព្រៃកោងកាង ។

៤-ការកាប់បំផ្លាញផ្តួលរំលំដើមឈើព្រៃលិចទឹក និងព្រៃកោងកាង ឬ គាស់រំលើងប្រមូលគល់ឈើព្រៃលិចទឹក និងព្រៃកោងកាង ។

៥-ការប្រមូល ដឹកជញ្ជូន និងការធ្វើសន្និធិឈើ អុស ធ្យូង ប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ឬ ពាណិជ្ជកម្ម ។

៦-ការសាងសង់ឡ រោងសិប្បកម្ម មូលដ្ឋានកែច្នៃ និងរោងចក្រគ្រប់ប្រភេទ ដែលប្រើប្រាស់វត្ថុធាតុដើមជាប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាង ។

**មាត្រា ២៩._**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានទទួលសិទ្ធិធ្វើអាជីវកម្មឡូត៍នេសាទ ត្រូវមានកាតព្វកិច្ចរក្សាការពារព្រៃលិចទឹក និងទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងនាទីឡូត៍នេសាទ ។

# ជំពូកទី ៧
# ការគ្រប់គ្រងអាជីវកម្មនេសាទ

**មាត្រា ៣០._**

ការធ្វើនេសាទ ត្រូវកំណត់តាមឧបករណ៍នេសាទបីប្រភេទ :

១-ឧបករណ៍នេសាទគ្រួសារ ។

២-ឧបករណ៍នេសាទសិប្បកម្ម ។

៣-ឧបករណ៍នេសាទឧស្សាហកម្ម ។

ប្រភេទឧបករណ៍នេសាទខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣១._**

ការធ្វើនេសាទជាលក្ខណៈគ្រួសារ អាចប្រព្រឹត្តទៅបានគ្រប់ពេលវេលានៅក្នុងកន្លែងនេសាទបម្រុង នៅក្នុងកន្លែងនេសាទគ្រួសារ នៅក្នុងឡូត៍នេសាទនៃដែននេសាទទឹកសាបក្នុងរដូវបិទនេសាទ ឬ នៅក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទគ្រួសារ ។

ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម អាចប្រព្រឹត្តទៅបានតែនៅក្នុងកន្លែងនេសាទបម្រុងនៃដែននេសាទទឹកសាប ឬ នៅក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទសិប្បកម្ម ។

ការធ្វើនេសាទជាលក្ខណៈឧស្សាហកម្ម អាចប្រព្រឹត្តទៅបានតែនៅក្នុងឡូត៍នេសាទនៃដែននេសាទទឹកសាប ឬ នៅក្នុងដែននេសាទសមុទ្រដោយប្រើឧបករណ៍នេសាទឧស្សាហ-កម្ម ។

**មាត្រា ៣២._**

ការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទទឹកសាប ឬ សមុទ្រលើកលែងតែការធ្វើនេសាទជាលក្ខណៈគ្រួសារត្រូវ :

១-មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ ។

២-មានកាតព្វកិច្ចបង់ពន្ធ និងថ្លៃឈ្នួលនេសាទជូនរដ្ឋ ។

៣-គោរពតាមបទបញ្ញាដែលមានចែងក្នុងលិខិតអនុញ្ញាតឱ្យធ្វើនេសាទ ។

ការប្រគល់ឡូត៍នេសាទឱ្យធ្វើអាជីវកម្ម អាចប្រព្រឹត្តទៅបានតាមការវិនិយោគ តាមការដេញថ្លៃជាសាធារណៈ ឬ ជួលតាមការព្រមព្រៀងចំពោះឡូត៍នេសាទ ដែលគ្មានអ្នកដេញថ្លៃ ។

នីតិវិធីនៃការវិនិយោគ ការដេញថ្លៃជាសាធារណៈ ឬ ការជួលតាមការព្រមព្រៀង និងការបង់ថ្លៃឈ្នួលនេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៣.–**

បន្ថែមលើច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធទៅលើការគ្រប់គ្រងនាវា អាជីវករនេសាទទាំងអស់ដែលប្រើប្រាស់នាវានេសាទក្នុងដែននេសាទនៃព្រះរាជាណាចក្រកម្ពុជា ត្រូវសុំចុះបញ្ជីនាវា និងឧបករណ៍បរិក្ខារបម្រើការធ្វើនេសាទពីរដ្ឋបាលជលផល បន្ទាប់ពីបានត្រួតពិនិត្យតាមគោលការណ៍បច្ចេកទេស ។

បទបញ្ញាបច្ចេកទេសនៃការគ្រប់គ្រងនាវានេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋ-មន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៤.–**

គ្រប់សកម្មភាពធ្វើអាជីវកម្មនេសាទ ធ្វើវារីវប្បកម្ម ធ្វើសន្និធិ កែច្នៃ និងទិញ លក់ផលផលិតផលជលផលដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវមានសៀវភៅសម្រាប់កត់ត្រាស្ថិតិដែលចេញដោយរដ្ឋបាលជលផលមានសមត្ថកិច្ច ។

សៀវភៅកត់ត្រាស្ថិតិនេះ ចាំបាច់ត្រូវមានការកត់ត្រាស្ថិតិឱ្យបានទៀងទាត់ជារៀងរាល់ថ្ងៃ និងត្រូវចុះហត្ថលេខាបញ្ជាក់ពីរដ្ឋបាលជលផលមានសមត្ថកិច្ចរៀងរាល់ខែ ។

**មាត្រា ៣៥.–**

ការធ្វើសន្និធិផល ផលិតផលជលផលក្នុងរដូវបិទនេសាទ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត ។

អាជីវករនេសាទត្រូវដាក់ពាក្យសុំធ្វើសន្និធិទៅរដ្ឋបាលជលផលយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃមុនរដូវបិទនេសាទ ។

**មាត្រា ៣៦.-**

ការបង្កើតទីតាំងទិញ លក់ សន្និធិ ឬ កន្លែងកែច្នៃផល ផលិតផលជលផល តាមទ្រង់ទ្រាយសិប្បកម្ម ត្រូវមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផលមានសមត្ថកិច្ច ។

ការបង្កើតទីតាំងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយឧស្សាហកម្ម ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៧.-**

ការបង្កើតផែត្រីដែលជាកន្លែងប្រមូលផ្តុំ ចែកចាយ ធ្វើពាណិជ្ជកម្មផល ផលិតផលជលផល ត្រូវមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផលមានសមត្ថកិច្ច ។

វិធាននៃការបង្កើត និងការគ្រប់គ្រងផែត្រី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣៨.-**

ការធ្វើអាជីវកម្មនេសាទ ឬ វារីវប្បកម្មរបស់ជនបរទេស ត្រូវស្ថិតនៅក្រោមកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បន្ទាប់ពីបានទទួលគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

## ជំពូកទី ៨
## ការធ្វើអាជីវកម្មនេសាទក្នុងដែននេសាទទឹកសាប

**មាត្រា ៣៩.-**

ការធ្វើអាជីវកម្មនេសាទក្នុងឡូត៍នេសាទ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត ហើយត្រូវធ្វើតែនៅក្នុងរយៈពេលបើកនេសាទដែលមានកំណត់ក្នុងសៀវភៅបន្ទុក ឬ លិខិតអនុញ្ញាតឱ្យធ្វើនេសាទ និងត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក ។

គំរូសៀវភៅបន្ទុកឡូត៍នេសាទដែលបានរៀបចំឡើងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤០.–**

ក្នុងរដូវបើកនេសាទ ទីតាំងនេសាទទាំងឡាយដែលធ្វើកាត់ផ្លូវទឹកក្នុងឡូត៍នេសាទ ត្រូវបើកមុខទឹកសម្រាប់ឱ្យជលយានគ្រប់ប្រភេទអាចធ្វើចរាចរណ៍បាន ហើយមិនត្រូវធ្វើឱ្យទឹកចាល់នៅមុខរបាំងទេ ។

ក្នុងរដូវបិទនេសាទ ត្រូវរុះរើ និងដកចេញនូវទីតាំងនេសាទទាំងឡាយដែលនៅក្នុងឡូត៍នេសាទឱ្យបានមុនថ្ងៃទី ១៥ ខែ មិថុនា ចំពោះតំបន់ដែលស្ថិតនៅខាងជើងខ្សែស្របទន្លេចតុមុខ និងមុនថ្ងៃទី ១៥ ខែ កក្កដា ចំពោះតំបន់ដែលស្ថិតនៅខាងត្បូងខ្សែស្របទន្លេចតុមុខ ។

**មាត្រា ៤១.–**

ហាមឃាត់ៈ

១-ការធ្វើនេសាទជាលក្ខណៈសិប្បកម្ម ឬ ឧស្សាហកម្មនៅក្នុងរដូវបិទនេសាទ ។

២-ការធ្វើនេសាទជាលក្ខណៈឧស្សាហកម្មនៅក្នុងកន្លែងនេសាទបម្រុង ។

៣-ការធ្វើនេសាទក្នុងកន្លែងនេសាទបម្រុងដោយប្រើឧបករណ៍គ្រប់ប្រភេទរួមផ្សំដោយរបាំងព្រួលដែលមានបណ្តោយលើសពីហាសិប (៥០) ម៉ែត្រ ឬ លាតសន្ធឹងលើសពីពីរភាគបី (២/៣) នៃទទឹងមុខទឹក ឬ ធ្វើឱ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទ ។

៤-ការប្រើសាច់មង អួន ឬ លួសសំណាញ់ដែលមានក្រឡាតូចជាងបួន (៤) សង្ទីម៉ែត្រ ធ្វើជារបាំងរួមផ្សំ ឬ ជំនួសរបាំងព្រួល ។

៥-ការធ្វើនេសាទដោយប្រើឧបករណ៍ដាយចាប់ត្រី ឬ ដាយចាប់បង្កងខុសទីតាំងកំណត់របស់ឡូត៍ដោយចាប់ត្រី ឬ ដាយចាប់បង្កង ។

**មាត្រា ៤២.–**

ផ្ទុយនឹងបទប្បញ្ញត្តិដែលមានចែងក្នុងចំណុច ៣ មាត្រា ៤១ នៃច្បាប់នេះ ការធ្វើនេសាទនៅក្នុងកន្លែងនេសាទបម្រុងដោយលបណ ឬ វ៉ាវដែលមានប្រវែងតិចជាងប្រាំរយ (៥០០)ម៉ែត្រនៅក្នុងបឹងទន្លេសាប អាចអនុញ្ញាតឱ្យធ្វើបានពីថ្ងៃទី ១ ខែ កុម្ភៈ ដល់ថ្ងៃទី ២០ ខែ ឧសភា នៅក្នុងកន្លែងដែលមានចម្ងាយយ៉ាងច្រើនបំផុតបួន (៤) គីឡូម៉ែត្រ ពីមាត់ច្រាំង និងមួយ(១)គីឡូម៉ែត្រយ៉ាងតិចពីព្រៃប្រទល់កន្លែងអភិរក្សជលផល ហើយនិងនៅក្នុងតំបន់ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ការបោះទីតាំងលបបណា ឬ រ៉ាវនេះ មិនត្រូវធ្វើឱ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទទេ ។

ទីតាំងលបបណា ឬ រ៉ាវទាំងឡាយ ត្រូវដកចេញឱ្យអស់មុនថ្ងៃទី ៣១ ខែឧសភា ដាច់ខាត ។

**មាត្រា ៤៣.–**

ការធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួន ទោះជាមួយវង់ ឬ ច្រើនវង់តភ្ជាប់គ្នាក៏ដោយ អាចប្រព្រឹត្តទៅបាន លុះត្រាតែអួននោះមានបណ្តោយតិចជាង :

-បីរយ(៣០០)ម៉ែត្រ ចំពោះកន្លែងនេសាទបម្រុងនៅក្រៅបឹងទន្លេសាប

-ប្រាំមួយរយ (៦០០) ម៉ែត្រ ចំពោះកន្លែងនេសាទបម្រុងនៅក្នុងបឹងទន្លេសាប ។

មិនអនុញ្ញាតឱ្យធ្វើនេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋ នៅក្នុងកន្លែងនេសាទដែលធ្វើឱ្យវិខានដល់ការធ្វើអាជីវកម្មឡូត៍នេសាទ និងនៅក្នុងកន្លែងនេសាទដែលមានទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ ។

កន្លែងនេសាទដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៤.–**

ការធ្វើនេសាទជាលក្ខណៈគ្រួសារនៅក្នុងកន្លែងនេសាទគ្រួសារដែលជាបឹងតូចៗស្ថិតក្នុងនាទីឡូត៍នេសាទនារដូវបើកនេសាទអាចប្រព្រឹត្តទៅបានលុះត្រាតែគោរពតាមបទបញ្ញាបច្ចេកទេសដែលកំណត់ដោយរដ្ឋបាលជលផល ។

## ជំពូកទី ៩
## ការធ្វើអាជីវកម្មនេសាទក្នុងដែននេសាទសមុទ្រ

**មាត្រា ៤៥.–**

ការធ្វើអាជីវកម្មនេសាទគ្រប់ប្រភេទនៅក្នុងដែននេសាទសមុទ្រ លើកលែងតែការនេសាទជាលក្ខណៈគ្រួសារ អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាត និងអនុវត្តតាមលក្ខខណ្ឌដែលមានចែងនៅក្នុងសៀវភៅនាវានេសាទ ។

គំរូសៀវភៅនាវានេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## មាត្រា ៤៦.–

ការបោះទីតាំងនេសាទ ឬ ដាក់ឧបករណ៍នេសាទគ្រប់ប្រភេទដែលលាតសន្ធឹងធ្វើឱ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទ ត្រូវហាមឃាត់ ។

ការបោះទីតាំងនេសាទ ឬ ដាក់ឧបករណ៍នេសាទគ្រប់ប្រភេទដែលលាតសន្ធឹងទទឹងព្រែក ស្ទឹង ឬ ផ្លូវទឹកនៃតំបន់ឆ្នេរសមុទ្រ ត្រូវបើកមុខទឹកមួយភាគបី (១/៣) ឬ យ៉ាងតិចបំផុតពីរភាគបី (២/៣) នៅពេលទឹកនាច ដើម្បីទុកឱ្យជលយានគ្រប់ប្រភេទអាចធ្វើចរាចរណ៍បាន។

ទីតាំងនេសាទ ឬ ឧបករណ៍នេសាទដូចមានចែងក្នុងកថាខណ្ឌទី ២នៃមាត្រានេះ ត្រូវរុះរើចេញមិនលើសពីដប់ប្រាំ (១៥) ថ្ងៃ គិតចាប់ពីថ្ងៃផុតកំណត់នៃលិខិតអនុញ្ញាត ។

## មាត្រា ៤៧.–

អាជីវករនេសាទសមុទ្រ ត្រូវផ្ទេរផលនេសាទនៅតាមកំពង់ផែនេសាទ ដែលបានអនុញ្ញាតដោយរដ្ឋបាលជលផល ។

នាវានេសាទបរទេស ដែលមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទនៅក្នុងដែននេសាទសមុទ្រ ត្រូវផ្តល់ព័ត៌មានដល់រដ្ឋបាលជលផលមុននឹងចូលសិចតក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខខណ្ឌផ្សេងៗសម្រាប់ការផ្ទេរផលនេសាទ និងការចូលសិចតនៃនាវានេសាទបរទេស ត្រូវកំណត់តាមបទបញ្ជាបច្ចេកទេសរបស់រដ្ឋបាលជលផល ។

## មាត្រា ៤៨.–

ផ្អែកតាមព័ត៌មានវិទ្យាសាស្ត្រដ៏ជាក់លាក់ដែលបញ្ជាក់អំពីការធ្វើនេសាទបាន និងកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់ផលស្តុកធនធានជលផល រដ្ឋបាលជលផលមានសិទ្ធិផ្អាកសកម្មភាពនេសាទបន្ទាន់ជាបណ្តោះអាសន្ន និងលើកសំណើពិនិត្យឡើងវិញលើកិច្ចព្រមព្រៀងនេសាទនោះ ដើម្បីសុំសេចក្តីសម្រេចពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤៩.-**

ការធ្វើនេសាទដែលប្រើឧបករណ៍នេសាទអួនអូសដោយកម្លាំងម៉ាស៊ីននៅក្នុងកន្លែងនេសាទតាមឆ្នេរត្រូវហាមឃាត់ លើកលែងតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់រដ្ឋបាលជលផលដើម្បីធ្វើការសិក្សា ពិសោធន៍ ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ។

**មាត្រា ៥០.-**

ហាមឃាត់ដាច់ខាត ការរៀបចំឧបករណ៍នេសាទដែលមានលក្ខណៈត្រៀមធ្វើនេសាទនៅក្នុងដែននេសាទសមុទ្រ ចំពោះនាវានេសាទទាំងឡាយណាដែលគ្មានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទ ។

គ្មាននាវានេសាទណាដែលបំពាក់ឧបករណ៍អួនអូស ឬ ឈ្នាងអូសគ្រឹក្រឡាហ្វូល ដែលអូស ឬ រុញដោយកម្លាំងម៉ាស៊ីន ត្រូវបានអនុញ្ញាតឱ្យចូលក្នុង ឬ ឆ្លងកាត់កន្លែងនេសាទតាមឆ្នេរបានឡើយ ។ អាចអនុញ្ញាតបានលុះត្រាតែនាវានេសាទទាំងនោះ បានរៀបចំទុកដាក់ឧបករណ៍នេសាទ តាមរបៀបមួយដែលមិនទាន់ត្រៀមជាស្រេចសម្រាប់ធ្វើនេសាទ ឬ នាវានេសាទទាំងនោះ ត្រូវបានអនុញ្ញាតដូចករណីដែលមានចែងក្នុងមាត្រា ៤៩ នៃច្បាប់នេះ ។

**មាត្រា ៥១.-**

ការផ្តល់សិទ្ធិឱ្យធ្វើអាជីវកម្មនេសាទ ឬ សិក្សាស្រាវជ្រាវធនធានជលផលនៅក្នុងដែននេសាទសមុទ្រអន្តរជាតិ ត្រូវបំពេញបែបបទតាមទម្រង់នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ ។

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិធ្វើអាជីវកម្ម ឬ សិក្សាស្រាវជ្រាវធនធានជលផលនៅក្នុងដែននេសាទសមុទ្រអន្តរជាតិ ត្រូវគោរពតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ ។

**មាត្រា ៥២.-**

ហាមឃាត់ៈ

១-ការធ្វើនេសាទ ឬ ការធ្វើអាជីវកម្មផ្សេងៗទៀតដែលប៉ះពាល់ ឬ រំខានដល់ការលូតលាស់នៃស្មៅសមុទ្រ ឬ ផ្កាថ្ម ។

២-ការប្រមូលផល ការទិញ ការលក់ ការដឹកជញ្ជូន និងការធ្វើសន្និធិផ្កាថ្ម ។

៣-ការចូលសិចត ឬ ការបោះយុថ្កានៅក្នុងតំបន់ផ្កាថ្ម ។

៤-ការបំផ្លាញស្មៅសមុទ្រ ឬ ផ្កាថ្មដោយសកម្មភាពផ្សេងៗទៀត ។

គ្រប់សកម្មភាពក្នុងចំណុចទី ១ ចំណុចទី ២ និងចំណុចទី ៣ ខាងលើអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ១០
## ការគ្រប់គ្រងវារីវប្បកម្ម

**មាត្រា ៥៣.–**

ការធ្វើវារីវប្បកម្មទឹកសាបដូចខាងក្រោម អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល :

១-ស្រះដែលមានផ្ទៃក្រឡាសរុប លើសពីប្រាំពាន់(៥.០០០)ម៉ែត្រក្រឡា ។

២-ស៊ងដែលមានផ្ទៃក្រឡាសរុប លើសពីពីរពាន់(២.០០០)ម៉ែត្រក្រឡា ។

៣-បែដែលមានផ្ទៃក្រឡាសរុប លើសពីដប់ប្រាំ(១៥)ម៉ែត្រក្រឡា ។

ការធ្វើវារីវប្បកម្មក្រពើ កន្ធាយ អណ្តើក កង្កែប អន្ទង់ ពស់ដែលបង្កកំណើតក្នុងទឹក ឬ ប្រភេទធនធានជលផលដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៤.–**

ការធ្វើវារីវប្បកម្មសមុទ្រដូចខាងក្រោម អាចប្រព្រឹត្តទៅបានលុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល :

១-បែដែលមានផ្ទៃក្រឡាសរុប លើសពីម្ភៃ (២០) ម៉ែត្រក្រឡា ។

២-ស្រែបង្គា ឬ ស្រះត្រី ដែលមានផ្ទៃក្រឡាសរុបលើសពីប្រាំពាន់ (៥.០០០) ម៉ែត្រក្រឡា ។

៣-វារីរុក្ខជាតិគ្រប់ប្រភេទ ដែលមានផ្ទៃក្រឡាទឹកសរុបលើសពីប្រាំពាន់ (៥០០០) ម៉ែត្រក្រឡា ។

៤-វារីសត្វផ្សេងទៀតដែលមានផ្ទៃក្រឡាទឹកសរុបលើសពីបីពាន់ (៣.០០០) ម៉ែត្រក្រឡា ។

ការធ្វើវារីវប្បកម្មអណ្ដើកសមុទ្រ ឬ ប្រភេទធនធានជលផលដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៥.–**

ការធ្វើវារីវប្បកម្មត្រីលំអគ្រប់ប្រភេទដូចខាងក្រោម អាចប្រព្រឹត្តទៅបាន លុះត្រាតែមានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល៖

១-ប្រភេទត្រីលំអពូជក្នុងប្រទេស លើសពីមួយម៉ឺន (១០.០០០) ក្បាល ។

២-ប្រភេទត្រីលំអពូជក្រៅប្រទេសលើសពីប្រាំពាន់ (៥.០០០) ក្បាល ។

ត្រីលំអគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៥៦.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានបំណងធ្វើវារីវប្បកម្មគ្រប់ប្រភេទដូចមានចែងក្នុងមាត្រា ៥៣ មាត្រា ៥៤ និងមាត្រា ៥៥ នៃច្បាប់នេះ ត្រូវដាក់ពាក្យសុំមករដ្ឋបាលជលផលមានសមត្ថកិច្ច និងត្រូវអនុវត្តតាមបទបញ្ញាបច្ចេកទេសវារីវប្បកម្មដែលកំណត់ដោយប្រធានរដ្ឋបាលជលផលថ្នាក់កណ្ដាល ។

រូបវន្តបុគ្គល ឬ នីតិបុគ្គលធ្វើវារីវប្បកម្មគ្រប់ប្រភេទដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវចុះបញ្ជីក្នុងសៀវភៅស្ថិតិវារីវប្បកម្មដោយមន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច ។

**មាត្រា ៥៧.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលធ្វើវារីវប្បកម្មគ្រប់ប្រភេទ ត្រូវរក្សាគុណភាពដី ទឹក វារីជីវសាស្ត្រ បរិស្ថាន និងហាមបង្ហូរវត្ថុធាតុ សារធាតុពុល ឬ បង្កសកម្មភាពផ្សេងៗ ដូចមានចែងក្នុងមាត្រា២២ នៃច្បាប់នេះ ។

**មាត្រា ៥៨.-**

ការនាំចូលពូជវារីសត្វ ឬ វារីរុក្ខជាតិគ្រប់ប្រភេទពីបរទេស ក្នុងគោលបំណងធ្វើវារីវប្បកម្ម អាចប្រព្រឹត្តទៅបាន លុះត្រាតែមានការអនុញ្ញាតពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល បន្ទាប់ពីបានពិនិត្យគុណភាព និងវាយតម្លៃលើគំរូសំណាកដោយមន្ទីរពិសោធន៍របស់រដ្ឋបាលជលផល ។

## ជំពូកទី ១១
## សហគមន៍នេសាទ

**មាត្រា ៥៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានសិទ្ធិរួមគ្នាបង្កើតសហគមន៍នេសាទនៅតាមមូលដ្ឋានរបស់ខ្លួន ដោយឈរលើគោលការណ៍ស្ម័គ្រចិត្តដើម្បីចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព ។

វិធានដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦០.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិប្រគល់ផ្នែកណាមួយនៃដែននេសាទឱ្យទៅសហគមន៍ដែលរស់នៅក្នុង ឬ ក្បែរដែននេសាទក្រោមរូបភាពជាកន្លែងនេសាទសហគមន៍ ។

**មាត្រា ៦១.-**

ខណ្ឌរដ្ឋបាលជលផល តាមរយៈដំណើរការពិគ្រោះយោបល់ជាមួយសមត្ថកិច្ចពាក់ព័ន្ធដទៃទៀតមានភារកិច្ចសិក្សារៀបចំដែននេសាទដើម្បីបង្កើតជាកន្លែងនេសាទសហគមន៍ ដោយកំណត់ព្រំប្រទល់ច្បាស់លាស់ និងមានទំហំសមស្របផ្អែកតាមលទ្ធភាពធនធានជលផល និងតម្រូវការប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ។

នាយខណ្ឌរដ្ឋបាលជលផល មានសិទ្ធិសម្រេចចុះ ឬ លុបកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយសហគមន៍មូលដ្ឋានណាមួយដែលរស់នៅក្នុង ឬ ក្បែរដែននេសាទ ។ កិច្ច

ព្រមព្រៀងនេះ ត្រូវមានសុពលភាពមិនលើសពីរយៈពេលបី (៣) ឆ្នាំ តែអាចពន្យារបាន ដោយផ្អែកលើរបាយការណ៍ពិនិត្យ និងវាយតម្លៃឡើងវិញរបស់ថ្នាក់ផ្នែករដ្ឋបាលជលផល ។

**មាត្រា ៦២.-**

កន្លែងនេសាទសហគមន៍ ត្រូវបានគ្រប់គ្រងដោយធានានិរន្តរភាពដោយសហគមន៍នេសាទ ស្របតាមផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍វិធានសហគមន៍នេសាទ និងគោលការណ៍ណែនាំអំពីសហគមន៍នេសាទ ។ រដ្ឋបាលជលផលត្រូវផ្តល់ជំនួយបច្ចេកទេសតាមការស្នើសុំរបស់សហគមន៍មូលដ្ឋាន និងត្រូវតាមដានត្រួតពិនិត្យការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវរៀបចំដោយសហគមន៍មូលដ្ឋាននិងមានការយល់ព្រមពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ហើយនិងត្រូវពិនិត្យឡើងវិញជារៀងរាល់បី (៣) ឆ្នាំម្តង ឬ មុនពេលកំណត់ក្នុងករណីចាំបាច់ ។

សហគមន៍នេសាទគ្មានសិទ្ធិលក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឬ ធ្វើការផ្ទេរកន្លែងនេសាទសហគមន៍បានឡើយ ។

គោលការណ៍ណែនាំអំពីសហគមន៍នេសាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិរំសាយកន្លែងនេសាទសហគមន៍តាមការចាំបាច់ណាមួយសម្រាប់ផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ១២
## ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មផល ផលិតផលជលផល

**មាត្រា ៦៤.-**

ការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមានលិខិតអនុញ្ញាត និងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលជលផលមានសមត្ថកិច្ច ។

វិធាននៃការដឹកជញ្ជូនផល ផលិតផលជលផលដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៥.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដឹកជញ្ជូនផល ផលិតផលជលផល ត្រូវបង់ថ្លៃបុព្វលាភលើផល ផលិតផលជលផលឱ្យរដ្ឋបាលជលផល លើកលែងតែសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ ឬ ការស្រាវជ្រាវ ។

អត្រានៃថ្លៃបុព្វលាភលើផល ផលិតផលជលផល ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

យថាប្រភេទនៃផលិតផលជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៦៦.–**

ការនាំចេញនូវផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម អាចប្រព្រឹត្តទៅបានលុះត្រាតែមាន :

១-លិខិតអនុញ្ញាតពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

២-លិខិតអនុញ្ញាតឱ្យនាំចេញពីអាជ្ញាធរគ្រប់គ្រងសាយតេសនៃកម្ពុជា ចំពោះប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ ទោះពុំមានជាលក្ខណៈពាណិជ្ជកម្មក៏ដោយ ។

៣-វិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផល ផ្អែកតាមតម្រូវការនៃប្រទេសនាំចូល ។

**មាត្រា ៦៧.–**

ការនាំចូលនូវផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មអាចប្រព្រឹត្តទៅបានលុះត្រាតែមាន :

១-លិខិតអនុញ្ញាតពីប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

២-លិខិតអនុញ្ញាតឱ្យនាំចេញពីអាជ្ញាធរគ្រប់គ្រងសាយតេសនៃប្រទេសនាំចេញ ចំពោះប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ ទោះពុំមានជាលក្ខណៈពាណិជ្ជកម្មក៏ដោយ ។

៣-វិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផលរបស់ប្រទេសនាំចេញ ។

## មាត្រា ៦៨.-

ការនាំចេញ ការនាំចូល ការទិញ ការលក់ ការដឹកជញ្ជូន ការកែច្នៃ និងការធ្វើសន្និធិប្រភេទផល ផលិតផលជលផលកំពុងរងគ្រោះថ្នាក់ អនុញ្ញាតបានតែចំពោះផល ផលិតផលជលផលដែលបានមកពីការធ្វើវារីវប្បកម្ម និង/ ឬ ផ្អែកទៅតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៦៤ មាត្រា ៦៥ មាត្រា ៦៦ និងមាត្រា ៦៧ នៃច្បាប់នេះ និង អនុសញ្ញាសាយតេស ។

ប្រភេទផល ផលិតផលជលផលដែលកំពុងរងគ្រោះថ្នាក់ត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៦៩.-

ហាមឃាត់ ៖

១-ការទិញ ការលក់ ការកែច្នៃ ការធ្វើសន្និធិ និងការដឹកជញ្ជូនផល ផលិតផលជលផលដែលបានមកពីការធ្វើនេសាទដោយខុសច្បាប់ ឬ ដោយប្រើឧបករណ៍នេសាទខុសច្បាប់ ។

២-ការដឹកជញ្ជូនផល ផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្មដោយគ្មានលិខិតអនុញ្ញាត ឬ ខុសខ្លឹមសារនៃលិខិតអនុញ្ញាតជាអាទិ៍ យថាប្រភេទ បរិមាណ សុពលភាព ចំណុចទីតាំងនៃទិសដៅ និង/ ឬ ផ្លូវដែលត្រូវឆ្លងកាត់ និងប្រភេទនៃមធ្យោបាយដឹកជញ្ជូន ។

៣-ការដឹកជញ្ជូនឧបករណ៍នេសាទហាមឃាត់នៅក្នុងតំបន់គ្រប់គ្រងជលផល ។

៤-ការដឹកជញ្ជូនផលផលិតផលជលផលក្នុងរដូវបិទនេសាទដោយពុំមានភ្ជាប់លិខិតអនុញ្ញាតឱ្យសន្និធិ ឬ ពុំបានកាត់ចេញនូវបរិមាណដឹកជញ្ជូនពីលិខិតអនុញ្ញាតឱ្យសន្និធិ ។

## ជំពូកទី ១៣
## អំពីលិខិតអនុញ្ញាត

**មាត្រា ៧០.–**

លិខិតអនុញ្ញាតទាំងឡាយដែលប្រើប្រាស់ក្នុងវិស័យជលផល និងការបែងចែកសិទ្ធិទទួលខុសត្រូវក្នុងការចេញលិខិតអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៧១.–**

គំរូលិខិតអនុញ្ញាត ទម្រង់ និងបែបបទនៃលិខិតដែលប្រើប្រាស់ជាផ្លូវការក្នុងវិស័យជលផល ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ជំពូកទី ១៤
## នីតិវិធីដោះស្រាយបទល្មើសជលផល

**មាត្រា ៧២.–**

បទល្មើសជលផលជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតដោយឡែកដូចមានចែងក្នុងច្បាប់នេះ ។

មន្ត្រីរដ្ឋបាលជលផល មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតរាល់បទល្មើសជលផល និងចងក្រងសំណុំរឿងប្ដឹងទៅតុលាការមានសមត្ថកិច្ច ។

ការស្រាវជ្រាវ ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ជាសមត្ថកិច្ចរបស់រដ្ឋបាលជលផល ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ។

## មាត្រា ៧៣.–

នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល មន្ត្រីរដ្ឋបាលជលផលត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និងត្រូវមានលិខិតបញ្ជាបេសកកម្ម ។

មន្ត្រីរដ្ឋបាលជលផលត្រូវធ្វើសច្ចាប្រណិធានចំពោះមុខអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដើម្បីទទួលនីតិសម្បទាបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ។

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើនិងចុះហត្ថលេខាលើកំណត់ហេតុបទល្មើសជលផលតាមដែនសមត្ថកិច្ចរបស់ខ្លួន ។

សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលជលផលត្រូវកំណត់ដោយអនុក្រឹត្យ ។

## មាត្រា ៧៤.–

អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរគយ និងវដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួលនិងជួយផ្តល់កម្លាំងសហការក្នុងការស្រាវជ្រាវ ត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ឬ ថែរក្សាវត្ថុតាងបទល្មើសជលផលជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច ។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចដូចមានចែងក្នុងកថាខណ្ឌខាងលើនេះបានជួបប្រទះនូវបទល្មើសជលផលជាក់ស្តែង អាជ្ញាធរទាំងនោះ :

១-ត្រូវជូនព័ត៌មានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចដែលនៅជិតបំផុត ។

២-អាចឃាត់ខ្លួនជនប្រព្រឹត្តបទល្មើស និងដកហូតទុកវត្ថុតាងនៃបទល្មើសជាបណ្តោះអាសន្ន រួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលជលផលដែលទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី ។

៣-មិនត្រូវប្រមូលប្រាក់ពិន័យ ឬរឹបអូសវត្ថុតាងនៃបទល្មើសជលផលដោយផ្ទាល់ឡើយ ។

**មាត្រា ៧៥.–**

ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចមានសិទ្ធិដូចតទៅ:

១-ត្រួតពិនិត្យការធ្វើអាជីវកម្មនេសាទ និងការធ្វើវារីវប្បកម្មគ្រប់ប្រភេទ ។

២-ត្រួតពិនិត្យការដឹកជញ្ជូន ផែត្រី កន្លែងកែច្នៃ កន្លែងធ្វើសន្និធិ ឬ ទីតាំងទិញលក់ផល ផលិតផលជលផល ។

៣-បញ្ឈប់ និងត្រួតពិនិត្យលើគ្រប់មធ្យោបាយ ដែលសង្ស័យថាមានផ្ទុកវត្ថុតាងនៃបទល្មើសជលផល ។

៤-ចូលត្រួតពិនិត្យ ឬ ឆែកឆេរគ្រប់ទីកន្លែង រួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ផែត្រី ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយរថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ។

៥-សាកសួរបុគ្គលនានាអំពីព័ត៌មានដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសជល-ផល ។

៦-ដកហូតឃាត់ទុកជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះ បើសិនជាបុគ្គលកាន់កាប់លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

ចំពោះមន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិដូចតទៅ :

១-លែង រក្សាទុកជាប្រយោជន៍សាធារណៈ ឬ បំផ្លាញចោលនូវផល ផលិតផលជលផលល្មើសច្បាប់ដែលបានដកហូត ឃាត់ទុក និងលក់ចំពោះវត្ថុតាងណាដែលងាយខូចខាត ដោយមានការចូលរួមជាសាក្សីពីអាជ្ញាធរមូលដ្ឋាន ឬ សមត្ថកិច្ចនានាដែលនៅជិតនោះដោយមានកំណត់ហេតុត្រឹមត្រូវ ។

២-បំផ្លាញចោលដោយមានកំណត់ហេតុត្រឹមត្រូវនូវវត្ថុតាងនៃបទល្មើសជលផលមានជាអាទិ៍ ឧបករណ៍នេសាទហាមឃាត់ ឬ ឧបករណ៍នេសាទ ឬ សម្ភារៈ បរិក្ខារល្មើសច្បាប់ ឬ ឡផ្សងប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាង ។

៣-ក្នុងករណីបទល្មើសជាក់ស្តែង ចូលឆែកឆេរនៅក្នុងទីធ្លាអាគារ ឬ ក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

## មាត្រា ៧៦.–

ក្នុងករណីបទល្មើសជលផលជាក់ស្តែង មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចមានសិទ្ធិដកហូតឃាត់ទុកជាបណ្តោះអាសន្ន ៖

១-ផល ផលិតផលជលផលដែលបានមកពីការធ្វើអាជីវកម្មនេសាទ ការធ្វើវារីវប្បកម្ម ការកែច្នៃ ការធ្វើសន្និធិ ការទិញ ការលក់ ផៃត្រី ឬ ការដឹកជញ្ជូន ដែលល្មើសនឹងច្បាប់នេះ ។

២-ផល អនុផលព្រៃលិចទឹក និងព្រៃកោងកាងដែលបានមកពីការកាប់ ការឆ្ការ ការរាន ការឈូសឆាយដោយល្មើសនឹងច្បាប់នេះ ។

៣-ឧបករណ៍នេសាទ និងមធ្យោបាយរួមផ្សំដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

៤-ប្រភេទផល ផលិតផលជលផលកំពុងរងគ្រោះថ្នាក់ ។

៥-សម្ភារៈបរិក្ខារ ឬ មធ្យោបាយដឹកជញ្ជូននានាដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសជលផល ឬ យកចេញបរិក្ខារណាមួយសម្រាប់ដំណើរការនាវា ឬ យានយន្ត ។

៦-ឯកសារផ្សេងៗ ដែលពាក់ព័ន្ធបទល្មើសជលផល ។

៧-លិខិតអនុញ្ញាតគ្រប់ប្រភេទ ក្នុងករណីដែលអ្នកទទួលសិទ្ធិតាមលិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌មាន សិទ្ធិសម្រេចឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសជលផលបានរយៈពេល៤៨ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ ។

## មាត្រា ៧៧.–

ការកសាងសំណុំរឿងនៃបទល្មើសជលផល ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

ទម្រង់បែបបទនៃកំណត់ហេតុបទល្មើសជលផល ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

## មាត្រា ៧៨.–

វត្ថុតាងនៃបទល្មើសជលផល ត្រូវបានកំណត់ដូចខាងក្រោម ៖

១- ផល ផលិតផលជលផល និងឧបករណ៍នេសាទ ឬ ផល អនុផលព្រៃលិចទឹក និងព្រៃកោងកាងដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស ។

២- សម្ភារៈ បរិក្ខារ និងមធ្យោបាយដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

វត្ថុតាងដែលមន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចបានដកហូតឃាត់ទុកជាបណ្ដោះអាសន្ន ត្រូវតែរក្សាទុករហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ប្រាក់ពិន័យអន្តរការណ៍ ឬ តាមការជំនុំជម្រះរបស់តុលាការ ។

ក្នុងករណីមិនអាចទុកយូរបានបណ្ដាលមកពីការពុកផុយហួតហែង ធ្វើឱ្យបាត់បង់បរិមាណ និងគុណភាព មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចអាចលក់វត្ថុតាងទាំងនោះយកប្រាក់មកតម្កល់ទុកបាន ។

ក្នុងពេលកំពុងប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស អ្នកបើកបរមធ្យោបាយអូស ឬ រុញ ឬ ដឹកជញ្ជូនវត្ថុតាងនៃបទល្មើសដែលគ្មានម្ចាស់នៅជាមួយ ត្រូវឃាត់ខ្លួនជាបណ្ដោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និងអ្នកសមគំនិត ។

## មាត្រា ៧៩.–

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និងពាក់ឋានន្តរសក្តិ នៅពេលចូលរួមសវនាការរបស់តុលាការ ។

## មាត្រា ៨០.–

នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ពាក់ព័ន្ធនឹងសំណុំរឿងបទល្មើសជលផលមានសិទ្ធិ និងកាតព្វកិច្ចចូលបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសជលផលនោះជូនតុលាការ ។

## មាត្រា ៨១.–

អាជ្ញាយុកាលនៃបទល្មើសជលផល ត្រូវស្របតាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ ។

**មាត្រា ៨២.–**

បុគ្គលដែលប្រព្រឹត្តបទល្មើសជលផលដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ។

បុគ្គលដែលបានផ្តល់មធ្យោបាយ ឬ បានបញ្ជា ឬ បានសម្រួលឱ្យជនណាមួយប្រព្រឹត្តបទល្មើសជលផល ត្រូវចាត់ទុកថាជាអ្នកសមគំនិតហើយត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះដូចគ្នានឹងអ្នកប្រព្រឹត្តបទល្មើសផ្ទាល់ដែរ ។

**មាត្រា ៨៣.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេសដែលបានប្រព្រឹត្តបទល្មើសជលផលក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៨៤.–**

មន្ត្រីរដ្ឋបាលជលផលដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មានសិទ្ធិផ្អាកសកម្មភាពនេសាទនៅក្នុងទីតាំងនេសាទទាំងមូល ឬ មួយផ្នែកជាបណ្តោះអាសន្ន ដើម្បីចាត់ការតាមនីតិវិធី ក្នុងករណីរូបវន្តបុគ្គល ឬ នីតិបុគ្គលនោះប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ល្មើសនឹងកិច្ចសន្យា ឬ កិច្ចព្រមព្រៀងរហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់ ។

**មាត្រា ៨៥.–**

បុគ្គលណាដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច មានសិទ្ធិប្តឹងតវ៉ាក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលសេចក្តីសម្រេចនេះ ទៅប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ។

ប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ត្រូវសម្រេចលើបណ្តឹងតវ៉ានោះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃយ៉ាងយូរគិតពីថ្ងៃទទួលបណ្តឹងតវ៉ានោះ ។ ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញដោយប្រធានរដ្ឋបាលជលផលថ្នាក់កណ្តាល ក្នុងករណីមិនអាចទទួលយកបាន ជននោះមានសិទ្ធិធ្វើបណ្តឹងតវ៉ាទៅតុលាការមានសមត្ថកិច្ច ។

ការតវ៉ាក្រោមមាត្រានេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាច និងដំណើរការអនុវត្តច្បាប់របស់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។

## ជំពូកទី ១៥
## ទោសប្បញ្ញត្តិ

### មាត្រា ៨៦.-

ការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារ ការផ្តន្ទាទោសពិន័យជាប្រាក់ ការរឹបអូស ការបំផ្លាញចោលវត្ថុតាងដែលសមត្ថកិច្ចជលផលប្រគល់ជូន និងការជួសជុលសំណងនៃការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

ការសម្រេចពិន័យអន្តរការណ៍ ការព្រមាន ការដកហូត ឬ ការព្យួរលិខិតអនុញ្ញាត ឬ កិច្ចព្រមព្រៀងជាសមត្ថកិច្ចរបស់រដ្ឋបាលជលផល ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ រដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ ។

មន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសជលផល ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលបន្ថែមលើទោសទណ្ឌដែលកំណត់ក្នុងច្បាប់នេះ ។

### មាត្រា ៨៧.-

រដ្ឋបាលជលផលមានសិទ្ធិសម្រេចអំពីការពិន័យអន្តរការណ៍ លើបទល្មើសជលផលដូចមានចែងក្នុងមាត្រា ៩២ មាត្រា ៩៣ មាត្រា ៩៤ មាត្រា ៩៥ មាត្រា ៩៦ និងមាត្រា ៩៧ នៃច្បាប់នេះ ។

ការពិន័យអន្តរការណ៍លើបទល្មើសជលផល អាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិនឱ្យលើសពីដប់ប្រាំ (១៥) ថ្ងៃគិតពីថ្ងៃចេញសេចក្តីសម្រេចពិន័យ ។

បែបបទ និងការផ្តល់សិទ្ធិសម្រេចពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ:

១-ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស ។

២-កម្រិតខូចខាតដល់បរិស្ថាន ។

៣-ចំនួននៃការប្រព្រឹត្តបទល្មើស ។

៤-បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល ។

៥-ការប្រព្រឹត្តល្មើសដោយចេតនា ។

**មាត្រា ៨៨.–**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រម ឬ សាលដីការបស់តុលាការ ឬ ប្រាក់បានមកពីការលក់វត្ថុតាង ដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋត្រូវបង់ចូលថវិកាជាតិ ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជលផលជាក់ស្តែងដែលបង្កមហន្តរាយធ្ងន់ធ្ងរណាមួយ ។

**មាត្រា ៨៩.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវផ្តន្ទាទោសដូចតទៅ :

១-ចំពោះបទល្មើសជលផលថ្នាក់ទី១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីបី (៣) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

២-ចំពោះបទល្មើសជលផលថ្នាក់ទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី(៣)ឆ្នាំ និង/ ឬ ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន(៥០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

៣-ចំពោះបទល្មើសជលផលថ្នាក់ទី ៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ខែ ទៅមួយ (១) ឆ្នាំ ឬ ពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅប្រាំលាន (៥.០០០.០០០) រៀល ។ វត្ថុតាងទាំងអស់អាចត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

៤-ការពិន័យអន្តរការណ៍ ការបំផ្លាញចោល ការដកហូត ឬ ការព្យួរកិច្ចព្រមព្រៀង ឬ លិខិតអនុញ្ញាត ។

តម្លៃទីផ្សារនៃផល ផលិតផលជលផល ឧបករណ៍នេសាទ និងកម្រិតសមាមាត្រនៃថ្លៃឈ្នួលនេសាទជាមូលដ្ឋានសម្រាប់ធ្វើការពិន័យ ត្រូវកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តឯកភាពទូទាំងប្រទេស ។

**មាត្រា ៩០.–**

រូបវន្តបុគ្គល ឬ នីតិបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសជលផលធ្វើឱ្យប៉ះពាល់ខូចខាតដល់អេកូឡូស៊ីជលផលនៅក្នុងដែននេសាទ ត្រូវចេញថ្លៃស្តារ ឬ ជួសជុលការខូចខាតឱ្យមានលក្ខខណ្ឌដូចដើមឡើងវិញ ។

**មាត្រា ៩១.–**

រដ្ឋបាលជលផលអាចចេញលិខិតព្រមាន ចំពោះសកម្មភាពល្មើសនៅក្នុងដែននេសាទដូចខាងក្រោម :

១-នេសាទជាលក្ខណៈគ្រួសារនៅកន្លែងនេសាទគ្រួសារដែលជាបឹងតូចៗ ស្ថិតនៅក្នុងនាទីឡូត៍នេសាទនារដូវបើកនេសាទ មិនគោរពទៅតាមបទបញ្ញាបច្ចេកទេសដែលកំណត់ដោយរដ្ឋបាលជលផល ។

២-ធ្វើវារីវប្បកម្មមិនតម្រូវឱ្យមានលិខិតអនុញ្ញាត តែមិនរាយការណ៍ឱ្យរដ្ឋបាលជលផល ។

៣-ប្រើប្រាស់លិខិតអនុញ្ញាតឱ្យធ្វើវារីវប្បកម្មមានលក្ខណៈអាជីវកម្មហួសសុពលភាព ។

**មាត្រា ៩២.–**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីពីរ (២) ដង ទៅបី (៣) ដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-នេសាទគ្រប់ប្រភេទដែលធ្វើឱ្យរាំងស្ទះចរាចរណ៍ត្រីចុះនៅតំបន់កបឹងទន្លេសាប ។

២-ចាប់ លក់ ទិញ ដឹកជញ្ជូន ប្រមូលផល កែច្នៃ និងធ្វើសន្និធិប្រភេទផល ផលិត-ផលជលផលពីធម្មជាតិដែលកំពុងរងគ្រោះថ្នាក់ ។

៣-បោះបង្គោលបង្កើតឡូត៍នេសាទថ្មី ឬ នេសាទជាលក្ខណៈឧស្សាហកម្ម នៅក្នុងកន្លែងនេសាទបម្រុង ។

៤-នាំចេញ នាំចូលប្រភេទផល ផលិតផលជលផលពីធម្មជាតិដែលកំពុងរងគ្រោះថ្នាក់ ។

៥-ប្រមូល ដឹកជញ្ជូន និងធ្វើសន្និធិឈើ អុស ធ្យូងប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាងជាលក្ខណៈអាជីវកម្ម ឬ ពាណិជ្ជកម្ម ។

ជនណាប្រព្រឹត្តបទល្មើសជលផលដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរ-ការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៩៣.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផល ជាប្រាក់ពីរ (២) ដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ធ្វើសន្និធិផល ផលិតផលជលផលគ្មានលិខិតអនុញ្ញាតលើស ឬ ខ្វះបរិមាណ និង/ ឬ ខុសយថាប្រភេទដែលកំណត់ក្នុងលិខិតអនុញ្ញាត ។

២-ផ្ទេរផលនេសាទនៅក្នុងដែននេសាទសមុទ្រក្នុងគោលបំណងនាំចេញដោយគ្មានការអនុញ្ញាត ។

៣-ដឹកជញ្ជូនផល ផលិតផលជលផលដោយគ្មានលិខិតអនុញ្ញាតលើសបរិមាណហួសសុពលភាព ខុសចំណុចទីតាំងនៃទិសដៅ និង/ ឬ ផ្លូវដែលត្រូវឆ្លងកាត់ ខុសមធ្យោបាយដែលកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។

៤-ដឹកជញ្ជូនផល ផលិតផលជលផលដោយពុំបានភ្ជាប់ប័ណ្ណបង់ប្រាក់បុព្វលាភ និង/ ឬ លិខិតអនុញ្ញាតឱ្យសន្និធិ ឬ ពុំបានកាត់ចេញនូវបរិមាណដឹកជញ្ជូនពីលិខិតអនុញ្ញាតឱ្យសន្និធិ ។

៥-នាំចេញ នាំចូលផល ផលិតផលជលផលគ្មានលិខិតអនុញ្ញាត ។

៦-នាំចេញ នាំចូលផល ផលិតផលជលផលគ្មានវិញ្ញាបនបត្របញ្ជាក់គុណភាពផ្នែករោគសាស្ត្រជលផល ។

៧-ធ្វើវារីវប្បកម្មគ្រប់ប្រភេទផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ដោយគ្មានលិខិតអនុញ្ញាត ខុសយថាប្រភេទ និង/ ឬ មិនអនុវត្តតាមបទបញ្ជាបច្ចេកទេស ។

៨-ទិញ លក់ផ្កាថ្ម ឬ ពពួកសិបកខ្យងខ្មៅតាំងលំអដែលជាប្រភេទកម្រ ។

ជនណាប្រព្រឹត្តបទល្មើសជលផលដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរ-ការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៩៤.–**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីមួយ (១) ដង ទៅពីរ (២) ដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-នេសាទដោយអួនអូសគូ ឬ អួនហ៊ុមរួមផ្សំភ្លើងធ្វើឱ្យត្រី ឬ វារីសត្វកុំ ។

២-នេសាទដោយឧបករណ៍ម៉ាញ់ នាម ជន មងក្រឡុក មងអូស ឈ្នាងអូស លៀស ឬ ខ្មៅនៅទឹកសាប និងឈ្នាងអូសគ្រែងឈាមនៅតំបន់ឆ្នេរសមុទ្រដែលអូស ឬ រុញដោយកម្លាំងម៉ាស៊ីនដោយគ្មានការអនុញ្ញាត ។

៣-នេសាទដោយប្រើឧបករណ៍ដាយចាប់ត្រី ឬ ដាយចាប់បង្កងខុសទីតាំងកំណត់របស់ឡូត៍ដាយចាប់ត្រី ឬ ដាយចាប់បង្កង ។

៤-នេសាទដោយអួនអូស ឬ ឈ្នាងអូសគ្រំក្រឡាហួលនៅក្រៅតំបន់អនុញ្ញាតឱ្យធ្វើនេសាទ ។

៥-ប្រើនាវានេសាទបរទេសដើម្បីធ្វើអាជីវកម្មនេសាទក្នុងដែននេសាទសមុទ្រកម្ពុជាមិនអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង ។

៦-ប្រើនាវានេសាទបរទេសដើម្បីធ្វើអាជីវកម្មនេសាទនៅក្នុងដែននេសាទសមុទ្រកម្ពុជាគ្មានលិខិតអនុញ្ញាត ។

៧-ចាប់ លក់ ទិញ ធ្វើសន្និធិ និងដឹកជញ្ជូនកូន ឬ ពងត្រី និងកូន ឬ ពងវារីសត្វផ្សេងទៀតដោយគ្មានលិខិតអនុញ្ញាត ។

៨-ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍នេសាទអួនអូសគូ ។

៩-មិនគោរពតាមផែនការគ្រប់គ្រង និងផែនការប្រមូលផល ផលិតផលជលផលប្រចាំឆ្នាំ ។

ជនណាប្រព្រឹត្តបទល្មើសជលផលចំណុចទី ១ ចំណុចទី ២ ចំណុចទី ៣ ចំណុចទី ៤ ចំណុចទី ៥ និងចំណុចទី ៦ នៅពេលយប់ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ពិន័យក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ហើយវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដងឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ពិន័យក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ហើយវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៩៥.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់សមាមាត្រទៅនឹងថ្លៃឈ្នួលនេសាទ ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ផ្ទេរលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្មនេសាទដោយគ្មានការអនុញ្ញាត ។

២-ប្រើប្រាស់នាវានេសាទគ្មានលិខិតអនុញ្ញាតរៀបចំឧបករណ៍នេសាទដែលមានលក្ខណៈត្រៀមធ្វើនេសាទក្នុងដែននេសាទសមុទ្រ ។

៣-ប្រើប្រាស់នាវានេសាទធ្វើនេសាទក្នុងដែននេសាទគ្មានលិខិតអនុញ្ញាត ឬ គ្មានសៀវភៅនាវានេសាទ ។

៤-ប្រើប្រាស់នាវានេសាទមានឧបករណ៍អួនអូសដោយកម្លាំងម៉ាស៊ីននៅក្នុងកន្លែងនេសាទតាមឆ្នេរដោយរៀបចំមានលក្ខណៈត្រៀមធ្វើនេសាទ ។

៥-ប្រើប្រាស់ទូក កាណូត កប៉ាល់នេសាទដោយគ្មានចុះបញ្ជីពីរដ្ឋបាលជលផល ។

៦-មិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅនាវានេសាទ ។

៧-នេសាទដោយលបលួច ឬ រ៉ាវក្នុងតំបន់កំណត់ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

៨-នេសាទជាលក្ខណៈសិប្បកម្មដោយអួនលើសពីបីរយ (៣០០) ម៉ែត្រ នៅក្រៅបឹងទន្លេសាប និងលើសពីប្រាំមួយរយ (៦០០) ម៉ែត្រ នៅក្នុងបឹងទន្លេសាប ។

៩-នេសាទជាលក្ខណៈសិប្បកម្មដោយអួននៅក្នុងកន្លែងនេសាទដែលទុកសម្រាប់តែប្រជាពលរដ្ឋនៅក្នុងកន្លែងដែលធ្វើឱ្យរំខានដល់ការធ្វើអាជីវកម្មក្នុងឡូត៍នេសាទ និងនៅក្នុងកន្លែងនេសាទដែលទម្លាប់ធ្វើអាជីវកម្មនេសាទដោយប្រើឧបករណ៍តូចៗ ។

១០-នេសាទជាលក្ខណៈសិប្បកម្មគ្មានលិខិតអនុញ្ញាត ខុសទីតាំងនេសាទ ខុសយថាប្រភេទឧបករណ៍នេសាទ ឬ ប្រើប្រាស់លិខិតអនុញ្ញាតហួសសុពលភាព ។

១១-នេសាទដោយលបលួច ឬ រ៉ាវ ខុសពេលកំណត់លើសពីប្រាំរយ (៥០០) ម៉ែត្រ រាំងស្ទះដល់ផ្លូវជលយានគ្រប់ប្រភេទ មិនដកចេញតាមពេលកំណត់ក្នុងតំបន់កំណត់ ។

១២-នេសាទជាលក្ខណៈឧស្សាហកម្មដោយគ្មានលិខិតអនុញ្ញាត ឬ ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

១៣-នេសាទប៉ះពាល់ ឬ ខូចខាតដល់ស្មៅសមុទ្រ ឬ ផ្កាថ្ម ។

១៤-មិនព្រមផ្អាកការធ្វើនេសាទតាមការបញ្ជាប់បណ្ដោះអាសន្នរបស់រដ្ឋបាលជលផលមានសមត្ថកិច្ច ។

១៥-ប្រើសាច់មង អួន ឬ លួសសំណាញ់ដែលមានក្រឡាតូចជាងបួន (៤) សង្ទីម៉ែត្រធ្វើរបាំងរួមផ្សំ ឬ ជំនួសរបាំងព្រួល ។

១៦-ធ្វើអាជីវកម្មនេសាទដោយមិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុកឡូត៍នេសាទ ឬ លិខិតអនុញ្ញាតឱ្យធ្វើនេសាទ ។

១៧-បោះរបាំងក្នុងឡូត៍នេសាទ ឬ ផ្លូវទឹកនៃតំបន់ឆ្នេរសមុទ្រដោយមិនបើកមុខទឹកឱ្យជលយានធ្វើចរាចរណ៍បាន ។

១៨-ធ្វើឱ្យចាល់ទឹកនៅមុខរបាំង ។

១៩-បោះទីតាំងឡូត៍ដាយខុសពីការកំណត់ ។

២០-ប្រើឧបករណ៍នេសាទ ឬ ពេលវេលានេសាទនៅក្នុងកន្លែងនេសាទសហគមន៍

ខុសពីការកំណត់របស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ និងវត្ថុតាងពិតប្រាកដទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

## មាត្រា ៩៦._

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផល ជាប្រាក់ពីប្រាំលាន(៥.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០) រៀល ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ប្រើប្រាស់លិខិតអនុញ្ញាតបង្កើតផែត្រី ទីតាំងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយឧស្សាហកម្ម ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

២-ប្រើប្រាស់នាវានេសាទបរទេសដែលមានលិខិតអនុញ្ញាតឱ្យធ្វើនេសាទចូលសំចតក្នុងដែននេសាទសមុទ្រកម្ពុជាពុំផ្តល់ព័ត៌មាន ឬ ពុំទាន់មានការអនុញ្ញាតពីរដ្ឋបាលជលផល ។

៣-បានទទួលសិទ្ធិធ្វើអាជីវកម្មឡូត៍នេសាទ មិនបានបំពេញកាតព្វកិច្ចរក្សាការពារព្រៃលិចទឹក និងទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងនាទីឡូត៍នេសាទ ។

៤-គាស់ កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដែននេសាទដោយគ្មានការអនុញ្ញាត ។

៥-ធ្វើនេសាទក្នុងកន្លែងនេសាទបម្រុងដោយប្រើឧបករណ៍គ្រប់ប្រភេទរួមផ្សំដោយរបាំងព្រួលដែលមានបណ្តោយលើសពីហាសិប (៥០) ម៉ែត្រ ឬ លាតសន្ធឹងលើសពីពីរភាគបី (២/ ៣) នៃទទឹងមុខទឹក ឬ ធ្វើឱ្យរាំងស្ទះផ្លូវជលយានគ្រប់ប្រភេទ ។

៦-សិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ឬ យកគំរូពិសោធន៍នៅក្នុងដែននេសាទគ្មានការអនុញ្ញាត ។

៧-ប្រមូលផល ធ្វើសន្និធិផ្កាថ្ម ឬ ចូលចតនាវា បោះយុថ្កានៅក្នុងតំបន់ផ្កាថ្មដោយគ្មានការអនុញ្ញាត ។

៨-បង្កើតផែត្រី ទីតាំងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយឧស្សាហកម្ម

គ្មានលិខិតអនុញ្ញាតពីរដ្ឋបាលជលផល ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២) ដង ឡើងទៅ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ ។

**មាត្រា ៩៧.-**

ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលជាប្រាក់ពីប្រាំរយពាន់ (៥០០.០០០) រៀល ទៅប្រាំលាន (៥.០០០.០០០) រៀល ឯវត្ថុតាងទាំងអស់ត្រូវប្រគល់ឱ្យសាមីជនវិញ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-មិនរុះរើ និងដកចេញទីតាំងនេសាទក្នុងឡូត៍នេសាទតាមកាលកំណត់ក្នុងច្បាប់នេះ ។

២-បង្កើតទីតាំងទិញ លក់ សន្និធិ ឬ កន្លែងកែច្នៃផល ផលិតផលជលផលតាមទ្រង់ទ្រាយសិប្បកម្មគ្មានលិខិតអនុញ្ញាត ឬ ហួសសុពលភាពនៃលិខិតអនុញ្ញាត ។

៣-ពុំមានសៀវភៅកត់ត្រាស្ថិតិផល ផលិតផលជលផល ។

៤-ពុំបានកត់ត្រាស្ថិតិផល ផលិតផលជលផល ឬ រាយការណ៍ជូនរដ្ឋបាលជលផលឱ្យ បានទៀងទាត់ ។

៥-ធ្វើវារីវប្បកម្មគ្រប់ប្រភេទមិនរក្សាគុណភាពដី ទឹក វារីជីវសាស្ត្រ និង បរិស្ថាន ដោយបង្ហូរកាកសំណល់ចូលទៅក្នុងដែននេសាទ ។

៦-តាំងទីលំនៅថ្មីដែលស្ថិតនៅតិចជាងពីរ (២) គីឡូម៉ែត្រ ពីកន្លែងអភិរក្សជលផល ។

៧-នាំចូលពូជវារីសត្វ ឬ វារីរុក្ខជាតិគ្រប់ប្រភេទគ្មានលិខិតអនុញ្ញាត ។

៨-ធ្វើនាវាចរណ៍ឆ្លងកាត់ ឬ ធ្វើសកម្មភាពផ្សេងៗទៀតក្នុងកន្លែងអភិរក្សជលផល ។

៩-ធ្វើអាជីវកម្មផ្សេងៗដែលប៉ះពាល់ ឬ ខូចខាតដល់ស្មៅសមុទ្រ ឬ ផ្កាថ្ម ។

ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រានេះចាប់ពីពីរ (២)ដង ឡើងទៅត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលជលផលទ្វេដងនៃប្រាក់ដែលត្រូវពិន័យអន្តរការណ៍ក្នុងមាត្រានេះ ។

## មាត្រា ៩៨.–

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១ ដែលត្រូវដាក់ពន្ធនាគារពីបី(៣) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និងវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល និងដកហូតកិច្ចព្រមព្រៀង ឬ លិខិតអនុញ្ញាត ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-កាប់ឆ្ការគាស់រាន ឈូសឆាយព្រៃលិចទឹក និងព្រៃកោងកាង ឬ ហ៊ុមព័ទ្ធកាន់កាប់ដីព្រៃលិចទឹក និងព្រៃកោងកាង ។

២-បង្កឱ្យភ្លើងឆេះ ឬ ដុតព្រៃលិចទឹក និងព្រៃកោងកាង ។

៣-ចាក់ចោល បោះចោល បង្ហូរ បាចពង្រាយសារធាតុពុល ឬ ប្រព្រឹត្តសកម្មភាពធ្វើឱ្យពុល ឬ បង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិនៅក្នុងដែននេសាទ ។

៤-នេសាទដោយឧបករណ៍ឆក់ គ្រឿងផ្ទុះ និងសារធាតុពុលគ្រប់ប្រភេទនៅក្នុងដែននេសាទ ។

៥-នេសាទដោយឧបករណ៍បូម បាច ពង្រីងផ្នែកណាមួយនៃដែននេសាទ ដែលបង្កមហន្តរាយដល់ធនធានជលផល ។

៦-នេសាទដោយឧបករណ៍ទំនើប ឬ ឧបករណ៍នេសាទដែលបង្កើតថ្មី ឬ របៀបនេសាទបែបថ្មី ឬ ឧបករណ៍នេសាទ ដែលគ្មានកំណត់ក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលនាំមកនូវការបំផ្លាញមច្ឆជាតិ ធនធានជលផល ប្រព័ន្ធអេកូឡូស៊ីជលផល ។

៧-នេសាទជាលក្ខណៈឧស្សាហកម្មក្នុងរដូវបិទនេសាទ ។

៨-នេសាទជាលក្ខណៈឧស្សាហកម្មក្នុងកន្លែងអភិរក្សជលផល ។

៩-ធ្វើទំនប់កាត់ ឬ លុបទន្លេ ស្ទឹង ព្រែក អូរ បឹង ត្រពាំង ប្រឡាយ អាងទឹក និង

អាងធម្មជាតិ ដែលអាចបង្កមហន្តរាយដល់ធនធានជលផលដោយគ្មានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

១០-បំផ្លាញស្មៅសមុទ្រ ឬ ផ្កាថ្ម និងធ្វើឱ្យអន្តរាយដល់អេកូឡូស៊ី ស្មៅសមុទ្រ ឬ ផ្កាថ្ម ។

១១-សាងសង់ឡ រោងសិប្បកម្ម មូលដ្ឋានកែច្នៃ និងរោងចក្រគ្រប់ប្រភេទដែលប្រើប្រាស់វត្ថុធាតុដើមជាប្រភេទឈើព្រៃលិចទឹក និងព្រៃកោងកាង ។

១២-បំផ្លិចបំផ្លាញ ឬ ធ្វើឱ្យខូចខាតអន្លង់ជ្រៅៗដែលជាជម្រក ឬ កន្លែងពងកូនរបស់វារីសត្វ ។

ជនណាប្រព្រឹត្តបទល្មើសជលផលចំណុចទី ៤ ចំណុចទី ៥ ចំណុចទី ៦ ចំណុចទី ៧ និងចំណុចទី ៨ នៅពេលយប់ ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសជលផលថ្នាក់ទី ១ នៃមាត្រានេះ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ១ ចាប់ពីពីរ(២)ដង ឡើងទៅ ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសជលផលថ្នាក់ទី១ នៃមាត្រានេះ ។

## មាត្រា ៩៩.-

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី២ ដែលត្រូវដាក់ពន្ធនាគារពីមួយ(១) ឆ្នាំ ទៅបី(៣)ឆ្នាំ និងពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន (៥០.០០០.០០០) រៀល និងវត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោលចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម ៖

១-បំផ្លាញ លាក់បាំង លក់ ឬ លួចវត្ថុតាងបទល្មើសជលផល ។

២-ផ្លាស់ប្តូរ រំកិល ឬ ដកកប់បង្គោលព្រំប្រទល់នៃតំបន់គ្រប់គ្រងជលផល ។

៣-ធ្វើឱ្យខូចខាត ឬ បំផ្លាញចោលទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងដែននេសាទ ។

៤-នេសាទជាលក្ខណៈសិប្បកម្មក្នុងកន្លែងអភិរក្សជលផល ។

៥-នេសាទដោយអួនអូសទឹកសាប និងឈិបយន្ត ។

៦-ជីកប្រឡាយ រណ្តៅ ឬ ស្រះទ្រង់ទ្រាយធំ ឬ សាងសង់សំណង់ថ្មីនានា ឬ បូមទឹក

ដែលអាចបង្កមហន្តរាយដល់ធនធានជលផលដោយគ្មានការសិក្សាវាយតម្លៃពីក្រសួងកសិ-កម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៧-ប្រើឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ សម្រាប់នេសាទជាលក្ខណៈសិប្ប-កម្ម ឬ ឧស្សាហកម្ម ។

៨-សកម្មភាពដទៃទៀតនៅក្នុងដែននេសាទដែលបង្កអន្តរាយដល់ប្រភពធនធានជលផល ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ២ ចំណុចទី ៤ និងចំណុចទី ៥ នៅពេលយប់ ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១ នៃច្បាប់នេះ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ២នៃមាត្រានេះចាប់ពីពីរ (២) ដងឡើងទៅ ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១នៃច្បាប់នេះ ។

### មាត្រា ១០០.-

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី២ ដែលត្រូវដាក់ពន្ធនាគារពីមួយ(១) ឆ្នាំ ទៅបី (៣) ឆ្នាំ និង/ ឬ ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន (៥០.០០០.០០០) រៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ប្រើខ្សែចងគ្រប់ប្រភេទនិងមធ្យោបាយផ្សេងទៀតដែលបង្កលក្ខណៈឱ្យត្រីផ្អើល។

២-នេសាទដោយប្រើទំនប់រួមផ្សំដោយឧបករណ៍នេសាទគ្រប់ប្រភេទដែលបង្កមហន្តរាយដល់ធនធានជលផល ។

៣-នេសាទដោយលបណ ឬ រាំវក្រៅតំបន់កំណត់ ។

៤-ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍ឆក់ ឬ ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ ។

៥-ដាំឈូកក្នុងឡូត៍នេសាទ ។

៦-ដាក់សម្រាស់ ឬ មធ្យោបាយផ្សេងទៀតធ្វើឱ្យត្រី ឬ វារីសត្វកុំ ។

៧-លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ឬ ផ្ទេរកន្លែងនេសាទសហគមន៍ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ២ នៃមាត្រានេះចាប់ពីពីរ (២) ដងឡើងទៅ ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ១ នៃច្បាប់នេះ ។

**មាត្រា ១០១.-**

ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ៣ ដែលត្រូវដាក់ពន្ធនាគារពីមួយ(១) ខែ ទៅមួយ (១) ឆ្នាំ ឬ ពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០) រៀល ទៅប្រាំលាន (៥.០០០.០០០) រៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-កាប់បំផ្លាញផ្តួលរំលំដើមឈើព្រៃលិចទឹក និងព្រៃកោងកាង ឬ គាស់រំលើងប្រមូលគល់ឈើព្រៃលិចទឹក និងព្រៃកោងកាង ។

២-ពង្រីកផ្ទៃដីកសិកម្ម ឬ ប្រើប្រាស់ដីក្នុងបំណងផ្សេងៗក្រៅពីកិច្ចអភិវឌ្ឍន៍វិស័យជលផលនៅក្នុងតំបន់លិចទឹកដែលត្រូវការពារ ។

៣-ពង្រីកផ្ទៃដីស្រែចំការ ឬ ស្រែអំបិលក្នុងដែននេសាទដោយគ្មានការអនុញ្ញាត ។

៤-ស្ថាបនាផ្លូវសាធារណៈ ដាក់តាំងមូលដ្ឋានសំណង់ ឬ លំនៅដ្ឋានគ្រប់ប្រភេទនៅក្នុងដែននេសាទ ។

៥-ដាំឈូកជាលក្ខណៈអាជីវកម្ម ឬ ពាណិជ្ជកម្មក្នុងតំបន់គ្រប់គ្រងជលផល ។

៦-ដឹកជញ្ជូនសម្រាស់ ។

៧-ផលិត ទិញ លក់ ដឹកជញ្ជូន រក្សាទុកឧបករណ៍នេសាទឈិបយន្ត ឬ អួនអូសទឹកសាប ។

៨-នេសាទជាលក្ខណៈសិប្បកម្មក្នុងរដូវបិទនេសាទ ។

៩-នេសាទជាលក្ខណៈគ្រួសារក្នុងកន្លែងអភិរក្សជលផល ។

១០-នេសាទដោយប្រើច្បូក សាង ស្ទូ ឬ ឧបករណ៍បាញ់ព្រួញដែលរួមផ្សំកែវផ្លុះ ។

១១-នេសាទដោយមងបោះ មងកាំង ឬ មងពស់ថ្នាន់គ្រប់ប្រភេទ ។

១២-នេសាទដោយប្រើមង ឬ អួនគ្រប់ប្រភេទដែលមានក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ (១,៥ ស.ម) ក្នុងដែននេសាទទឹកសាប ។

១៣-នេសាទដោយមងគ្រប់ប្រភេទដែលមានក្រឡាធំជាងដប់ប្រាំ (១៥) សង្ទីម៉ែត្រ ក្នុងដែននេសាទទឹកសាប ។

១៤-នេសាទដោយប្រើព្រួលគ្រប់ប្រភេទដែលមានចន្លោះពីត្រៀមមួយទៅត្រៀម មួយតូចជាងមួយសង្ទីម៉ែត្រកន្លះ(១,៥ ស.ម) ។

១៥-ទិញ លក់ កែច្នៃ ធ្វើសន្និធិ និងដឹកជញ្ជូនផល ផលិតផលជលផល ដែលបានមកពីការធ្វើនេសាទខុសច្បាប់ ឬ ដោយប្រើឧបករណ៍នេសាទខុសច្បាប់ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ៣ ចំណុចទី ៨ ចំណុចទី ៩ ចំណុចទី ១០ ចំណុចទី ១១ ចំណុចទី ១២ និងចំណុចទី ១៣ នៅពេលយប់ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ២ នៃមាត្រា ៩៩ នៃច្បាប់នេះ ។

ជនណាប្រព្រឹត្តបទល្មើសជលផលថ្នាក់ទី ៣ ចាប់ពីពីរ (២) ដងឡើងទៅ ត្រូវផ្តន្ទាទោសក្រោមបទល្មើសជលផលថ្នាក់ទី ២ នៃមាត្រា ៩៩ នៃច្បាប់នេះ ។

## មាត្រា ១០២.-

សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬ មន្ត្រីអាជ្ញាធរផ្សេងទៀត ដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬ ដោយប្រយោលជួយដល់អាជីវកម្មជលផល និងធ្វើសកម្មភាពគ្រប់បែបយ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលជលផល ឬ រាំងស្ទះដល់ការបំពេញភារកិច្ច និងកិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលជលផល ត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី (៣) ឆ្នាំ និង/ ឬ ពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ទៅហាសិបលាន (៥០.០០០.០០០) រៀល ។

## មាត្រា ១០៣.-

ចំពោះសកម្មភាពដូចខាងក្រោមដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលជលផល ត្រូវចាត់ទុកជាបទល្មើស និងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅបី (៣) ឆ្នាំ និង/ ឬ ពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅហាសិបលាន (៥០.០០០.០០០)រៀល :

១-ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

២-ចូលរួមទាំងស្រុង ឬ ដោយផ្នែក និងដោយផ្ទាល់ ឬ ដោយប្រយោល ក្នុង

សកម្មភាពណាមួយនៃអាជីវកម្មជលផលដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

៣-អនុគ្រោះចំពោះបទល្មើសជលផលថ្នាក់ទី ១ ។

៤-ប្រកបរបរអាជីវកម្មឡូត៍នេសាទ ទោះធ្វើជាម្ចាស់ទាំងស្រុងក្ដី ជាម្ចាស់ភាគហ៊ុនក្ដីក្នុងអំឡុងពេលស្ថិតនៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ។

៥-មិនបានរាយការណ៍ ឬ មិនបានដាក់ពាក្យបណ្ដឹងចំពោះបទល្មើសជលផលថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។

៦-ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬ ផ្ដល់ព័ត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសជលផលថ្នាក់ទី ១ ។

**មាត្រា ១០៤.–**

ជនណាដែលប្រព្រឹត្តអំពើក្លែងបន្លំគ្រប់ប្រភេទដែលទាក់ទងនឹងវិស័យជលផលត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ១៦

## ការអនុវត្តសាលក្រមតុលាការ

**មាត្រា ១០៥.–**

ការអនុវត្តសាលក្រម ឬ សាលដីកាស្ថាពរនៃបទល្មើសជលផល ជាភារកិច្ចរបស់រដ្ឋបាលជលផលមានសមត្ថកិច្ច លើកលែងតែទោសដាក់ពន្ធនាគារ ។

**មាត្រា ១០៦.–**

រាល់សម្រេចសាលក្រម ឬ សាលដីកានៃបទល្មើសជលផល ត្រូវចម្លងមួយច្បាប់ជូនរដ្ឋបាលជលផលមានសមត្ថកិច្ច ។

**មាត្រា ១០៧.–**

បន្ទាប់ពីសាលក្រម ឬ សាលដីកាចូលជាស្ថាពរ វត្ថុតាងដែលតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ ឬ បំផ្លាញចោល ត្រូវចាត់ចែងតាមនីតិវិធីដោយរដ្ឋបាលជលផល ។

## ជំពូកទី ១៧

## អវសានប្បញ្ញត្តិ

**មាត្រា ១០៨.–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០៩.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៦

នស.០៦០៥.២៤៨ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នាយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់និងនេសាទ**

**ហត្ថលេខា**

**ច័ន្ទ សារុន**

លេខ: ៤២៨ ខ.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាឌី តាន់

# ឧបសម្ព័ន្ធ

**កន្លែងនេសាទបម្រុង** : សំដៅដល់ផ្នែកមួយនៃដែននេសាទទឹកសាបដែលមិនមែនជាឡូត៍នេ-សាទ កន្លែងអភិរក្សជលផល នាទីព្រៃលិចទឹក កន្លែងនេសាទគ្រួសារ ឬទំនាបលិចទឹកក្នុងរដូវជំនោរឡើង។ កន្លែងនេសាទបម្រុងមិនត្រូវបានធ្វើការចាត់ថ្នាក់ជាតំបន់គ្រប់គ្រងជលផលជាក់លាក់ឡើយ ហើយត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទបានតែការនេសាទ ២ប្រភេទ គឺការនេ-សាទជាលក្ខណៈគ្រួសារ និងការនេសាទជាលក្ខណៈសិប្បកម្ម ។ កន្លែងនេសាទបម្រុងមានជាអាទិ៍ ទន្លេ ស្ទឹង ព្រែក បឹង អាងធម្មជាតិ ឬ ត្រពាំង ។ល។

**កន្លែងនេសាទសហគមន៍** : សំដៅដល់ដែននេសាទរបស់រដ្ឋដែលបានប្រគល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងរវាងនាយខណ្ឌរដ្ឋបាលជលផលជាមួយសហគមន៍ ឬក្រុមប្រជាពលរដ្ឋរស់នៅក្នុង ឬ ក្បែរដែននេសាទដែលពឹងផ្អែកលើការធ្វើនេសាទសម្រាប់ការចិញ្ចឹមជីវិត និងការប្រើប្រាស់ជាប្រពៃណី ហើយដែលធ្វើការគ្រប់គ្រង ឬ ប្រើប្រាស់កន្លែងនេសាទនោះប្រកបដោយនិរន្តរភាព ។

**កន្លែងអភិរក្សជលផល** : សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាប ឬ សមុទ្រ ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់សម្រាប់វារីសត្វ ឬ រុក្ខជាតិជ្រកពួនពងកូន រីកធំធាត់ ឬរីកលូតលាស់ ។ កន្លែងអភិរក្សជលផលជាថ្នាលពូជ និងជាតំបន់ការពារធនធានជលផលដែលពុំអាចអនុញ្ញាតឱ្យប្រព្រឹត្តសកម្មភាពដែលនាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ ក្រៅពីការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលស្របតាមគោលការណ៍ដ៏ត្រឹមត្រូវ ។

**ការកែច្នៃតាមទ្រង់ទ្រាយសិប្បកម្ម** : សំដៅដល់ការកែច្នៃទ្រង់ទ្រាយមធ្យមជាលក្ខណៈហត្ថកម្មដែលមានផល ផលិតផលជលផលចាប់ពីមួយ (១) តោនឡើងទៅ ក្នុងមួយ

(១)ឆ្នាំ ហើយប្រើកម្លាំងពលកម្មច្រើននាក់ដោយពុំមានការបែងចែកក្រុមពលកម្មដាច់ដោយឡែកច្បាស់លាស់ទេ ។

**ការកែច្នៃតាមទ្រង់ទ្រាយឧស្សាហកម្ម** : សំដៅដល់ការកែច្នៃទ្រង់ទ្រាយធំដែលប្រើកម្លាំងពលកម្មច្រើនក្រុមដាច់ដោយឡែកពីគ្នាទៅតាមខ្សែបណ្តាញផលិតកម្មផ្សេងៗគ្នា ។

**ការដឹកជញ្ជូនផលផលិតផលជលផលជាលក្ខណៈពាណិជ្ជកម្ម** : សំដៅដល់ការដឹកជញ្ជូនផល ផលិតផលជលផល :

ក) នៅក្នុងប្រទេស :

- ក្នុងរយៈពេលបើកនេសាទនូវផលជលផលទឹកសាបរស់ ឬស្រស់លើសពីពីររយ (២០០) គីឡូក្រាម ឬ ផលិតផលជលផលលើសពីហុកសិប (៦០) គីឡូក្រាម
- ក្នុងរយៈពេលបិទនេសាទនូវផលជលផលទឹកសាបរស់ ឬ ស្រស់លើសពីហុកសិប (៦០) គីឡូក្រាម ឬ ផលិតផលជលផលលើសពីម្ភៃ (២០) គីឡូក្រាម
- ផលជលផលសមុទ្ររស់ឬស្រស់លើសពីពីររយ(២០០)គីឡូក្រាម ឬផលិតផលជលផលលើសពីហុកសិប(៦០)គីឡូក្រាម ។

ខ) ដើម្បីនាំចេញ :

- គ្រប់ការនាំចេញផលជលផលរស់ ឬ ស្រស់ទោះបរិមាណតិចក្តី និងសំដៅដល់ផលិតផលជលផលលើសពីដប់ (១០) គីឡូក្រាម ។

គ) ដើម្បីនាំចូល :

- គ្រប់ការនាំចូលផលជលផលរស់ ឬ ស្រស់ ទោះបរិមាណតិចក្តី និងសំដៅដល់ផលិតផលជលផលលើសពីដប់ (១០) គីឡូក្រាម ។

**ការបង្កកំណើត** : សំដៅដល់ការរលាយចូលគ្នានៃកាម៉េតញីនិងកាម៉េតឈ្មោលបង្កើតបានជាស៊ីកូតមួយ ។

**ការពិន័យអន្តរការណ៍** : សំដៅដល់ការពិន័យដោយរដ្ឋបាលជលផលហើយអាចធ្វើបានតែក្នុងករណីជនល្មើសបានយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិដែលមានចែងក្នុងមាត្រា ៨៧ នៃច្បាប់នេះដោយមិនឆ្លងកាត់ស្ថាប័នតុលាការ ។

**ការនេសាទ** : សំដៅដល់ការប៉ុនប៉ង ការស្រាវជ្រាវ ការធ្វើសកម្មភាពដោយប្រើមធ្យោបាយនានា ដើម្បីទាក់ទាញ ចាប់ ដាក់អន្ទាក់ ធ្វើឱ្យរបួសធ្វើឱ្យងឹងើ សម្លាប់និងប្រមូលយកវារីសត្វពីក្នុងដែននេសាទ ។

**ការនេសាទជាលក្ខណៈគ្រួសារ** : សំដៅដល់ការនេសាទទ្រង់ទ្រាយតូចដែលប្រើប្រាស់ឧបករណ៍មានលក្ខណៈទោល ។
ការនេសាទជាលក្ខណៈគ្រួសារក៏ជាការនេសាទដែលមានលក្ខណៈជាប្រពៃណីហើយជាទូទៅពុំមែនសម្រាប់គោលបំណងធ្វើពាណិជ្ជកម្មទេ ។

**ការនេសាទជាលក្ខណៈសិប្បកម្ម** : សំដៅដល់ការនេសាទទ្រង់ទ្រាយមធ្យមប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈទោល ឬ ឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារហើយធ្វើសកម្មភាពនេសាទដោយកម្លាំងពលកម្មម្នាក់ ឬ ច្រើននាក់ ។ ក៏ប៉ុន្តែក្នុងការធ្វើនេសាទដោយកម្លាំងពលកម្មច្រើននាក់ ក៏ដោយ ក៏សកម្មភាពនោះមិនអាចបែងចែកក្រុមដោយឡែកពីគ្នាច្បាស់លាស់ឡើយហើយថែមទាំងអនុវត្តសកម្មភាពក្នុងពេលព្រមគ្នា ។

**ការនេសាទជាលក្ខណៈឧស្សាហកម្ម** : សំដៅដល់ការនេសាទទ្រង់ទ្រាយធំដែលប្រើប្រាស់ឧបករណ៍នេសាទមានលក្ខណៈជាបរិក្ខារហើយធ្វើសកម្មភាពនេសាទដោយប្រើប្រាស់កម្លាំងពលកម្មតាមក្រុមដាច់ដោយឡែកពីគ្នាហើយក្រុមនីមួយៗអាចប្រើពេលវេលាពលកម្មខុសគ្នា ។

**កែច្នៃផលនេសាទ** : សំដៅដល់ការដាក់បញ្ចូលផលនេសាទទៅក្នុងដំណើរការឧស្សាហកម្ម ឬ ផលិតកម្មទ្រង់ទ្រាយតូច ឬ ធំ ក្នុងគោលបំណងប្រែក្លាយលក្ខណៈដើមរបស់វា ឬ រក្សាទុកវាជាដើមដោយពុំរាប់បញ្ចូលនូវការកែច្នៃផលនេសាទទាំងឡាយដោយរោងចក្រធុនតូច ធំ មធ្យម សិប្បកម្ម ដែលបានធ្វើការវេចខ្ចប់ច្រកចូលក្នុងកំប៉ុង ឬ កែវ ដបបិទជិត ឬ មានសំបកវេចខ្ចប់បិទជិតដែលការពារបាននូវការចម្លងមេរោគផ្សេងៗ ។

**ជម្រក** : សំដៅដល់ទីកន្លែងសម្រាប់ជ្រកមួយជងមួយកាល ឬ អចិន្ត្រៃយ៍របស់មច្ឆជាតិ និងវារីសត្វ ទោះបីតំបន់ទឹកសាប ឬ សមុទ្រ ។ ទីជម្រកទាំងនោះរួមមាន : កន្លែងអភិរក្សជលផល អន្លង់ជ្រៅៗ តំបន់ព្រៃលិចទឹក តំបន់ផ្កាថ្ម តំបន់ស្មៅសមុទ្រ បឹងទន្លេសាប ស្រះ ឬ អន្លង់ជ្រៅៗនៅតាមវត្ត តំបន់ការពារធម្មជាតិ និងកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ ។

**ជលផល** : សំដៅដល់ឯកតានៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬ សិប្បនិម្មិត ក្រោមទម្រង់ជាដីលិចទឹកដែលគ្របដណ្តប់ទៅដោយទឹកអចិន្ត្រៃយ៍ ឬ ដំឡើង ឬ ទឹកជោរ នាច និងរុក្ខជាតិចម្រុះលិចទឹកព្រមទាំងធនធានជីវសាស្ត្រដូចជាវារីសត្វរួមទាំងផ្កាថ្ម វារីរុក្ខជាតិដែលបង្កកំណើតនៅក្នុងទឹក ។

**ជលយាន** : សំដៅដល់ឧបករណ៍អណ្តែតទឹកដែលប្រើប្រាស់សម្រាប់ផ្ទុក ឬ ជាមធ្យោបាយ មានជាអាទិ៍ ទូក កាណូត កប៉ាល់ សំពៅ សំប៉ាន ឬ ក្បូន ។

**តំបន់ទឹកជួរ** : សំដៅដល់កន្លែងដែលមានថ្មរកេតរក្ខូតនៅទន្លេមេគង្គ លើកាំពីពីខេត្តក្រចេះទៅព្រំប្រទល់ប្រទេសឡាវដែលមានអន្លង់ជ្រៅៗដែលបំលែងចរន្តទឹកឱ្យលឿន រួមទាំងរុក្ខជាតិលិចទឹក ដូចជាព្រៃអញ្ចែងជាដើម ដែលជាជម្រក និងជាកន្លែងពងកូននៃមេត្រីពូជ ។

**ទំនាបលិចទឹកនៅរដូវដីឡើង** : សំដៅដល់ដីទំនាបទទួលរបបទឹកទន្លេមេគង្គដែលមិនមែនជាទីតាំងឡូត៍នេសាទ ព្រៃលិចទឹក កន្លែងអភិរក្សជលផល កន្លែងនេសាទគ្រួសារ និងកន្លែងនេសាទបម្រុង រួមមាន វាលទំនាប វាលស្មៅ វាលស្រែចំការ និងដីដែលទឹកទន្លេមេគង្គឡើងដល់ ហើយដែលជាទីវាលទំនាបដ៏សំខាន់សម្រាប់មច្ឆជាតិធ្វើចរាចរណ៍រកកន្លែងពងកូននិងស្វែងរកចំណីនៅក្នុងរដូវបិទនេសាទ ។

**ទ្រព្យសម្បត្តិរបស់រដ្ឋនៅក្នុងដែននេសាទ** : សំដៅដល់ទ្រព្យសម្បត្តិសាធារណៈនិងឯកជនរបស់រដ្ឋនៅក្នុងដែននេសាទ ដូចជា ការិយាល័យ ស្នាក់ការ មធ្យោបាយធ្វើដំណើរ ដឹកជញ្ជូន និងប្រើប្រាស់របស់មន្ត្រីរដ្ឋបាលជលផលសម្រាប់អនុវត្តច្បាប់ បង្គោល ឬ ពោងព្រំប្រទល់តំបន់គ្រប់គ្រងជលផលជាដើម ។

**ធនធានជលផល** : សំដៅដល់អត្ថន័យដូចមានចែងក្នុងមាត្រា៤នៃច្បាប់នេះហើយដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញនិងនេសាទ ។

**នាទីព្រៃលិចទឹកនិងព្រៃកោងកាង** : សំដៅដល់ផ្ទៃដីលិចទឹកដោយរបបទឹកទន្លេមេគង្គ ឬ ដីលិចទឹកដោយរបបទឹកជោរ នាច របស់សមុទ្រដែលគ្របដណ្តប់ដោយព្រៃលិចទឹកនិងព្រៃកោងកាង ។ នាទីព្រៃលិចទឹកនិងព្រៃកោងកាងរាប់បញ្ចូលទាំងតំបន់លិចទឹកដែលត្រូវការពារ ។

**នាវានេសាទ** : សំដៅដល់ជលយានគ្រប់ប្រភេទដែលគេបំពាក់ឧបករណ៍នេសាទសម្រាប់នេសាទ ។

**ផលនេសាទកែច្នៃ** : សំដៅដល់ផលនេសាទដែលបានឆ្លងកាត់ការកែច្នៃរួចហើយ ។

**ផល ផលិតផល**

**ជលផល** : សំដៅដល់ផលដែលគេរុករក និងប្រមូលយកវាពីធម្មជាតិ មានវារីសត្វ និងវារីរុក្ខជាតិ ដូចជាមច្ឆជាតិ ផ្កាថ្ម សារាយជាដើម ដែលអាចហៅបានថាជាផលជលផល ។ ពេលដែលគេយកផលរុករកប្រមូលយកបានពីធម្មជាតិទៅកែច្នៃ គេនឹងទទួលបានផលិតផលកែច្នៃផលជលផល(ផលិតផលជលផល)ដែលមានជាអាទិ៍ផលនេសាទកែច្នៃ(ប្រហុក ផ្អក ត្រីឆ្អើរ ត្រីងៀត បង្គាក្រៀម ។ល។) ឬ សារាយក្រៀមជាដើម ។ ផលិតផលកែច្នៃផលជលផលទាំងនេះពុំបានរាប់បញ្ចូលនូវផលិតផលទាំងឡាយណាដោយរោងចក្រធុនតូច ធំ មធ្យមសិប្បកម្មដែលបានធ្វើការវេចខ្ចប់ច្រកចូលក្នុងកំប៉ុង ឬ កែវ ដបបិទជិត ឬ មានសំបកវេចខ្ចប់បិទជិតដែលការពារបាននូវការចម្លងមេរោគផ្សេងៗ ។

**ដៃត្រី** : សំដៅដល់ស្តង់ត្រី ឬ ឃឿត្រីជាផែបណ្តែតនៅជាប់មាត់ទឹក ឬ ជាស្តង់នៅលើគោក ដែលជាកន្លែងប្រមូល ធ្វើសន្និធិ ចែកចាយធ្វើពាណិជ្ជ-កម្មផល ផលិតផលជលផល ។

**ព្រៃលិចទឹក និង**
**ព្រៃកោងកាង** : សំដៅដល់ឯកតានៃប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬ សិប្បនិម្មិតក្រោមទម្រង់ជាដីលិចទឹក ដែលគ្របដណ្តប់ដោយរុក្ខជាតិចម្រុះ ទោះបីដុះដោយធម្មជាតិក្តី ឬ ដោយដាំក្តី រួមទាំងធនធានធម្មជាតិដទៃស្ថិតនៅក្នុងនោះ ដែលមានគោលបំណងប្រើប្រាស់សំខាន់ គឺជាជម្រកពង កូនរបស់ត្រី និងវារីសត្វទាំងអស់។ពុំត្រូវចាត់ទុកជាព្រៃលិចទឹកនិងព្រៃកោងកាង រួមមាន ដំណាំកសិកម្ម ឬ ដំណាំឧស្សាហកម្មនិងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

**វារីរុក្ខជាតិ** : សំដៅដល់រុក្ខជាតិទឹកតូចៗដែលកកើត ឬ ដុះ និងរីកលូតលាស់នៅក្នុងទឹក ព្រមទាំងហ្វ៊ីតូប្លង់តុងដោយប្រភេទខ្លះកកើត និងរីកលូតលាស់នៅស្រែទាប់បាត ប្រភេទខ្លះដុះនិងរីកលូតលាស់បណ្តែតទឹក

ប្រភេទខ្លះកកើត ឬដុះនៅស្រែទាប់បាត និងរីកលូតលាស់ស្លឹកដើមទង មែកនៅលើទឹកហើយប្រភេទខ្លះទៀតអាចរស់នៅលើគោកបានមួយរយៈពេលដែលទឹកនឹងរីងហួតអស់ ។

**វារីវប្បកម្ម** : សំដៅដល់ការភ្ញាស់ ការបង្កាត់ ការចិញ្ចឹម ការបំប៉នពងត្រី កូនត្រី ត្រី ឬ វារីសត្វ ឬ ការដាំ ការបណ្តុះពូជវារីរុក្ខជាតិក្នុងគោលបំណងធ្វើឱ្យកើនចំនួនឱ្យរីកលូតលាស់ ឬរីកធំធាត់វារីសត្វ ឬ វារីរុក្ខជាតិ ។

**វារីសត្វ** : សំដៅដល់ពួកសត្វបង្កកំណើតក្នុងទឹក មានជាអាទិ៍ មច្ឆជាតិ សិប្បីសត្វ ថលជលិកសត្វ បាណកសត្វ ឧរង្គសត្វ ថនិកសត្វ សត្វឥតឆ្អឹងកងផ្សេងទៀតព្រមទាំងពង កូនរបស់វា ដែលរស់នៅជាសិខាន់ក្នុងទឹក ។ ប្រភេទវារីសត្វត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**វារីសត្វគ្មានជីវិត** : សំដៅដល់សំណាកវារីសត្វ ឬ វារីសត្វដែលស្លាប់ ទោះជានៅខ្លួនទាំងមូល សរីរាង្គក្នុង សរីរាង្គក្រៅ បំណែកឆ្អឹងឬផលិតផលកែច្នៃក៏រាប់បញ្ចូលជាធនធានជលផល ។

**សត្វបង្កកំណើតក្នុងទឹក** : សំដៅដល់សត្វដែលត្រូវការលក្ខខណ្ឌចាំបាច់ក្នុងការបង្កកំណើតក្នុងទឹក រស់នៅអាស្រ័យដោយទឹក នៅក្នុងទឹក ឬ នៅក្បែរទឹក ជាមំសាសី តិណាសី ឬ សព្វាសី ដែលភាគច្រើនចិញ្ចឹមជីវិតដោយចំណីជាសត្វទឹក ឬ រុក្ខជាតិទឹក ។

**សន្និធិ** : សំដៅដល់ការរក្សាទុកមួយរយៈនូវផល ផលិតផលជលផលនៅក្នុងទីតាំងណាមួយក្នុងគោលបំណងលក់ផល ផលិតផលជលផលនោះឱ្យបានទទួលតម្លៃលើសហើយក៏ដើម្បីជៀសវាងការភាន់ច្រឡំរវាងផលរក្សាទុក និងផលដែលចាប់យកពីធម្មជាតិនៅក្នុងរដូវបិទនេសាទ។

**សម្រាស់** : សំដៅដល់គល់ ដើម ឬ មែកឈើ និងវត្ថុផ្សេងៗដែលអ្នកនេសាទយកទៅដាក់នៅក្នុងដែននេសាទទៅតាមទំហំផ្សេងៗដើម្បីបង្កើត

| | | |
|---|---|---|
| | | ជាជម្រកទាក់ទាញត្រីឱ្យប្រមូលផ្តុំនៅមួយកន្លែងរហូតដល់ពេលវេលាមួយសមស្របទើបគេធ្វើនេសាទដោយប្រើឧបករណ៍នេសាទហ៊ុមព័ទ្ធចាប់យកត្រី ។ |
| **សាយតេស** | : | សំដៅដល់អនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់។ |
| **ឡូត៍នេសាទ** | : | សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាបដែលផ្តល់នូវផលនេសាទហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់ដែលមានប្រព័ន្ធបឹង ព្រែក ព្រៃលិចទឹក ធនធានជលផល និងជីវចម្រុះ ដែលកំណត់នូវការរកកើត និងរីកធំធាត់របស់មច្ឆជាតិ វារីសត្វនិងវារីរុក្ខជាតិហើយនិងត្រូវបានកំណត់នូវទីតាំង និងពេលវេលាអាជីវកម្មជាក់លាក់ដោយមិនជះឥទ្ធិពលដល់ទីតាំងដទៃទៀត ។ |
| **អនុផលព្រៃលិចទឹក និងព្រៃកោងកាង** | : | សំដៅដល់ផលនៃរុក្ខជាតិមិនមែនឈើព្រៃលិចទឹកនិងព្រៃកោងកាងដែលផ្តល់ដោយព្រៃលិចទឹក និងព្រៃកោងកាង ។ អនុផលព្រៃលិចទឹក និងព្រៃកោងកាង នឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ |
| **អន្លង់ជ្រៅៗ** | : | សំដៅដល់រណ្តៅ ឬ អន្លង់ដែលមានជម្រៅជ្រៅ ភាគច្រើនស្ថិតនៅទន្លេមេគង្គលើ ដែលជាជម្រកចាំបាច់សម្រាប់ត្រីមេពូជជ្រក ពួននិងពង កូន បន្តពូជ ។ |
| **ឧបករណ៍ឆក់** | : | សំដៅដល់ឧបករណ៍នេសាទប្រើចរន្តអគ្គិសនី ឬ ឧបករណ៍បំលែងចរន្តពីភ្លើងអាគុយទៅចរន្តអគ្គិសនី ។ |
| **ឧបករណ៍នេសាទ** | : | សំដៅដល់បរិក្ខារ ឬ វត្ថុដែលអាចប្រើប្រាស់ក្នុងសកម្មភាពប្រមូលយកវារីសត្វមានជាអាទិ៍ មង អួន សន្ទូច លប អន្ទាក់ ពួ ខ្សែ កំសួលពោងផ្អស់ ឈើ ឬស្សី ម៉ាស៊ីន ភ្លើង នុយ ឬ សារធាតុគីមី ។ |

**ឧបករណ៍នេសាទគ្រួសារ** : សំដៅដល់ឧបករណ៍នេសាទដែលគេប្រើប្រាស់សម្រាប់ការនេសាទជាលក្ខណៈគ្រួសារ ។ ឧបករណ៍នេសាទគ្រួសារត្រូវបានបែងចែកដាច់ពីឧបករណ៍នេសាទសិប្បកម្ម ដោយលក្ខណៈសំគាល់តាមទ្រង់ទ្រាយ ទំហំ ចំនួន និងប្រភេទរបស់ឧបករណ៍នោះ ។ ឧបករណ៍នេសាទគ្រួសារនឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ឧបករណ៍នេសាទសិប្បកម្ម** : សំដៅដល់ឧបករណ៍នេសាទដែលគេប្រើប្រាស់សម្រាប់ការនេសាទជាលក្ខណៈសិប្បកម្ម ។ ចំពោះឧបករណ៍នេសាទមានលក្ខណៈទោលលក្ខណៈសម្គាល់របស់វាយោលទៅតាមទ្រង់ទ្រាយ ទំហំ ប្រភេទនិងចំនួននៃឧបករណ៍នោះ ។ ឧបករណ៍នេសាទសិប្បកម្មនឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ឧបករណ៍នេសាទហាមឃាត់** : សំដៅដល់ឧបករណ៍នេសាទដែលបំផ្លិចបំផ្លាញជាខ្លាំង ដល់ប្រភពធនធានជលផល ដែលមានជាអាទិ៍ ឧបករណ៍ឆក់សារធាតុពុលគ្រឿងផ្ទុះ ឧបករណ៍បូមពង្រីង ច្បូក រួមផ្សំកែវឆ្លុះ មងអួនក្រឡាតូចជាងមួយសង្ទីម៉ែត្រកន្លះ(១,៥ស.ម)ឧបករណ៍នេសាទស្បៃមុងអួនអូសគូ និងអួនហ៊ុមរួមផ្សំភ្លើងជាដើម ។

**ឧបករណ៍នេសាទឧស្សាហកម្ម** : សំដៅដល់ឧបករណ៍នេសាទដែលគេប្រើប្រាស់សម្រាប់ការនេសាទជាលក្ខណៈឧស្សាហកម្ម ។ ឧបករណ៍នេសាទឧស្សាហកម្មនឹងកំណត់ជាក់លាក់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។